# មជ្ឈមណ្ឌលឯកសារកម្ពុជា

## ង៉ាន់ សឿន ហៅ ស៊ាន់

*(សន្តិសុខគុកក្រាំងតាចាន់)*

*សម្ភាសជាមួយ **វ៉ាន់ សឿន** ភេទប្រុស អាយុ៤៨ឆ្នាំ*

*នៅភូមិជ្រៃ ឃុំលាយបូរ ស្រុកត្រាំកក់ ខេត្តតាកែវ*

*នៅថ្ងៃទី ៩ ខែ សីហា ឆ្នាំ ២០០៥*

*សម្ភាសដោយៈ ជួន សុភារិទ្ធ*

*ស៊ាន់ៈ* ឆ្លងកាត់មួយដំណាក់មកមួយដំណាក់ មិនដឹងធ្វើម៉េច ក្រោមបញ្ជាគេដែរ ជំនាន់នោះដូចដឹងស្រាប់ហើយ ។

*សុកគឿនៈ* ចង់ដឹងថាពូបានជួបប្រទះអីខ្លះ ដូចបានសួរអ្នកមុនៗហើយ ក្រែងលោពូបានដឹងអីផ្សេងពីគាត់អញ្ចឹងណា៎ ?

*ស៊ាន់ៈ* ខ្ញុំមិនសូវបាននៅកន្លែងដែរ គ្រាន់តែបានថារស់នៅក្នុងហ្នឹងជាមួយគេមែន តែខ្ញុំហ្នឹងដើរតែក្រៅហ្នឹង រត់តែសំបុត្រទេ ហើយធ្វើរបាយការណ៍មក ដូចជាឃុំស្រែរនោង, ឃុំញ៉ែងញ៉ង, ឃុំត្រាំកក់, ឃុំត្រពាំងធំជើង, ឃុំត្រពាំងធំត្បូងហ្នឹងណា៎ សេះមួយហ្នឹងជិះចង់ងាប់ហើយកាលហ្នឹងជំនាន់ហ្នឹងមានអី មានតែសេះ ហើយកង់កញ្ចាស់មួយគ្មានប្រាំង គ្មានអីទេ ។

*ភារិទ្ធៈ* ចុះពូមានអីចង់សួរនាំដែរ ហើយពេលដែលពូនិយាយហ្នឹងមានការភ័យខ្លាចអីទេ?

*ស៊ាន់ៈ* ខ្ញុំអត់មានភ័យអីទេ ។

*ភារិទ្ធៈ* អញ្ចឹងខ្ញុំចង់ឲ្យពូបំភ្លឺការពិតហ្នឹងណា ដូចខ្ញុំនិយាយពីគោលបំណងអញ្ចឹង ។

*ស៊ាន់ៈ* ហើយចង់និយាយពីគោលបំណងហ្នឹង ចង់និយាយពីការធ្វើទារុណកម្មឬយ៉ាងម៉េច?

*ភារិទ្ធៈ* ទាំងអស់ និយាយពីប្រវត្តិផ្ទាល់ខ្លួនពូ ពូបានឃើញ បានលឺអីពីជំនាន់ហ្នឹង ហើយកាលពីនៅក្រាំងតាចាន់ ទៅឆ្នាំណាអីឆ្នាំណា៎ ហ្នឹងចាំខ្ញុំសួរ ប៉ុន្តែ?

*ស៊ាន់ៈ* ហ្នឹងដូចជាភ្លេចដែរហើយ ប្រហែលជាឆ្នាំ៧៦ ដំណាលគ្នាហ្នឹងខុចហ្នឹង ។

*សុជាតិៈ* ឌុចធំ ឬឌុចតូច?

*ស៊ាន់ៈ* ឌុចធំគេទៅមុនបានជួបឌុចធំហ្នឹងដែរហេះ?

*សុជាតិៈ* បាទ! បានជួប គាត់នៅត្រពាំងរនាប ។

ស៊ាន់៖ ហើយរឿងអញ្ចឹងមានតែខាងខុចធំហ្នឹងទេ គេសួរចម្លើយសួរអី ខ្ញុំគ្មានបានពាក់ព័ន្ធទៅសួរចម្លើយអីទេ ។

ភារិទ្ធៈ អូ! ខុចធំហ្នឹងអ្នកសួរចម្លើយ?

ស៊ាន់៖ ហ្នឹងហើយ ហើយតាចេង ហ្នឹងតាអាន់ហ្នឹងបាត់ខ្លួនហើយ តាចេងគេបាញ់សម្លាប់នៅក្រាំងស្វែងនេះ ។

ភារិទ្ធៈ ឆ្នាំក្រោយ៧៩ហ្នឹង?

ស៊ាន់៖ ថ្ងៃហ្នឹងម៉ង ឆ្នាំ៧៩ហ្នឹង ពេលយើងរត់ហ្នឹង គាត់អត់រត់ណា៎ គាត់អត់រត់មិនមែនគាត់នៅហ្នឹងទេ គាត់មកផ្ទះគាត់នៅក្របីព្រៃទៅហើយ ហើយគាត់អត់រត់ទៅទៀត គេដកគាត់ចេញឆ្នាំ៧៧-៧៨ ពាក់ពន្ធជាមួយតាពេញ ។ ពាក់ព័ន្ធជាមួយតាពេញហ្នឹង គាត់ក៏ដូចថា កាលហ្នឹងតាសាន គាត់គណៈស្រុក គាត់ដកតាចេងហ្នឹងចេញ កាលហ្នឹងឈ្លោះប្រកែកគ្នារឿងសិទ្ធិអំណាចអីគេ កាលហ្នឹងសម្ព័ន្ធយុវករហ្នឹងណា៎ ។

ភារិទ្ធៈ បាទ ។

ស៊ាន់៖ ដល់ដូរកម្មវិធីទៅ ឲ្យគាត់ទៅនៅរោងមាន់ឯចម្ការសៀង ដល់នៅរោងមាន់ចម្ការសៀងក៏គាត់នឹកឃើញថា ពេល៧៩ហ្នឹងគេយកគាត់បកទៅវិញ ។ បកទៅវិញឈ្លោះប្រកែកគ្នាគេថា គណបក្សកាន់អំណាចហ្នឹងគេថា តាពេញហ្នឹងឡើងបក្សសម្ព័ន្ធយុវករហ្នឹង ដល់ឡើងបក្សអញ្ចឹង គេដកគាត់ចេញពីបក្សហ្នឹងទៅ ក៏គាត់ទៅនៅរោងមាន់ចម្ការសៀងទៅ ដល់គាត់មកវិញ នៅសហករណ៍ហ្នឹងបណ្ដោយទៅ ហើយដល់ពេលរត់គាត់អត់រត់ គាត់នឹកឃើញថាគេដកចេញយូរហើយណា៎ គាត់អត់មានអត់ករអីទេ រត់ទៅហ្នឹងគេទៅ ។

ភារិទ្ធៈ អញ្ចឹងអានេះជាប្រវត្តិដែលពូរៀបរាប់លម្អិតគ្រួសៗណា តែខ្ញុំចង់សួរពូតិចទៀត តែមុនហ្នឹងខ្ញុំសុំសួរពូជំនាន់ហ្នឹងមកណា ខ្ញុំសុំស្គាល់ឈ្មោះពូសិន

ស៊ាន់៖ វ៉ាន់ សឿន ។

ភារិទ្ធៈ ហើយពូអាយុប៉ុន្មានហើយ?

ស៊ាន់៖ ៤៨ហើយឆ្នាំហ្នឹង ។

ភារិទ្ធៈ ពូមានស្រុកកំណើតកើតជានៅឯណាដែរ?

ស៊ាន់៖ នៅភូមិជ្រៃហ្នឹងម៉ង ។

ភារិទ្ធៈ ឃុំអី?

ស៊ាន់៖ ឃុំលាយបូរ ។

ភារិទ្ធៈ ពីមុនមកគេហៅអញ្ចឹងដែរហីអី?

ស៊ាន់៖	ហៅអញ្ជីងដែរ ។

ភារិទ្ធ៖	ហើយពូរៀបការឆ្នាំណាដែរ?

ស៊ាន់៖	៧៩ ។

ភារិទ្ធ៖	កាលពីពូការឆ្នាំណា?

ស៊ាន់៖	ឆ្នាំ៧៩ អាយុ២២ ។

ភារិទ្ធ៖	គ្រួសារពូឈ្មោះអីដែរ?

ស៊ាន់៖	ម៉ម យី ។

ភារិទ្ធ៖	ហើយគាត់អាយុប៉ុន្មានដែរ?

ស៊ាន់៖	បងខ្ញុំមួយឆ្នាំ ៤៩ហើយ ។

ភារិទ្ធ៖	គាត់មានស្រុកកំណើតកើតជានៅឯណា?

ស៊ាន់៖	ភូមិជ្រៃហ្នឹងដែរ ។

ភារិទ្ធ៖	ហើយពូមានកូនចៅប៉ុន្មាននាក់?

ស៊ាន់៖	៨នាក់ ។

ភារិទ្ធ៖	ប្រុសប៉ុន្មានស្រីប៉ុន្មាន?

ស៊ាន់៖	ប្រុស៥ ស្រី៣ ។

ភារិទ្ធ៖	នៅជុំគ្នាទាំងអស់ហេះ?

ស៊ាន់៖	កូនការហើយប្រុសៗ២ នៅ៦ ។

ភារិទ្ធ៖	ហើយឪពុកម្ដាយពូ?

ស៊ាន់៖	នៅ ។

ភារិទ្ធ៖	ឪពុកឈ្មោះអី?

ស៊ាន់៖	ម៉ៅ សែន ។

ភារិទ្ធ៖	គាត់នៅរស់តើអី?

ស៊ាន់៖	នៅ ។

ភារិទ្ធ៖	នៅឯណាដែរ?

ស៊ាន់៖	ភូមិជ្រៃយើងដែរ ចុងលិច ។

ភារិទ្ធ៖	គាត់អាយុប៉ុន្មានហើយ?

ស៊ាន់៖	៧៤-៧៥ហើយ ។

ភារិទ្ធ៖	ចុះម្ដាយ?

សាន់ៈ ម្ដាយ ណាំ ដាន់ ។

ភារិទ្ធៈ អាយុប៉ុន្មានហើយ?

សាន់ៈ អាយុ៧៨ ។

ភារិទ្ធៈ គាត់នៅរស់ដែរ?

សាន់ៈ បាទ ។

ភារិទ្ធៈ អូ! ហើយមានបងប្អូនបង្កើតប៉ុន្មាននាក់ដែរ?

សាន់ៈ ៨ ។

ភារិទ្ធៈ មានប្រុសប៉ុន្មានស្រីប៉ុន្មាន?

សាន់ៈ ប្រុស៣ ស្រី១ ។

ភារិទ្ធៈ នៅរស់ទាំងអស់អី?

សាន់ៈ ទាំងអស់ តែខ្វាក់មួយ ។

ភារិទ្ធៈ ម៉េចបានជាខ្វាក់

សាន់ៈ លាប់កញ្ច្រិលអាហ្នឹងពីឆ្នាំ៧០ យើងរដ្ឋប្រហារ រត់ចុះរត់ឡើង អត់មានថ្នាំសង្កូវអី លាប់កញ្ច្រឹល ។

ភារិទ្ធៈ ចុះពូកាលពីឆ្នាំ៧០ហ្នឹង ពេលរដ្ឋប្រហារសម្ដេចហ្នឹង ពូនៅឯណាដែរ?

សាន់ៈ នៅភូមិជ្រៃហ្នឹង ។

ភារិទ្ធៈ កាលហ្នឹងធ្វើអីដែរ?

សាន់ៈ អត់មានធ្វើអីទេ នៅរៀន ។

ភារិទ្ធៈ អូ! នៅរៀនសាលាណា?

សាន់ៈ វត្តសូរ ហៅវត្តឧត្តមសូរិយាហ្នឹង ។

ភារិទ្ធៈ រៀនបានថ្នាក់ទីប៉ុន្មានដែរ?

សាន់ៈ ថ្នាក់ទី៩ ។

ភារិទ្ធៈ ហើយបន្ទាប់ពីរដ្ឋប្រហារទម្លាក់សម្ដេចហ្នឹង ភ្លាមមក មានហេតុការណ៍អីខ្លះកើតឡើងនៅក្នុងភូមិពូរស់នៅ?

សាន់ៈ កាលហ្នឹងទាហានខ្មែរក្រហមហ្នឹងទាហានលន់ណុល កាលហ្នឹងម្ដុំហ្នឹងអត់មាននរណាទៅទេឆ្នាំ៧១-៧២ ហ្នឹងអត់ទេ គេប្រទាញប្រទង់គ្នា ខ្ញុំរត់ទៅនៅវ៉ា នៅកន្ទែងឡ ទៅនៅផ្ទះបងប្អូននៅហ្នឹង ក្រោយមក ឆ្នាំ៧៣បានខ្ញុំរត់ទៅលិចវិញ ។

ភារិទ្ធៈ ទៅនៅវ៉ាហ្នឹងធ្វើអី?

សាន់៖ អត់មានធ្វើអីទេ ស៊ីឈ្នួលឃ្វាលទាគេ ។

ភារិទ្ធ៖ ទៅជាមួយគ្រួសារឪពុកម្ដាយតើអី?

សាន់៖ ទៅជាមួយម៉ែឪហ្នឹងហើយ ឆ្នាំ៧២ ។

ភារិទ្ធ៖ អូ! ទៅនៅហ្នឹងបានប៉ុន្មាន?

សាន់៖ ជិតមួយឆ្នាំ ។

ភារិទ្ធ៖ ចុះឆ្នាំ៧៣?

សាន់៖ ឆ្នាំ៧៣ខ្ញុំរត់ទៅលិចវិញ ។

ភារិទ្ធ៖ ម៉េចបានជារត់ទៅលិច?

សាន់៖ កាលហ្នឹងគេវៃចូលមកដល់ភ៉ាហើយហ្នឹង ។

ភារិទ្ធ៖ ខាងណា ខាងខ្មែរក្រហមហេះ?

សាន់៖ ខ្មែរក្រហម វៃចូលដល់ភ៉ាហ្នឹង តាកែវយើងនៅតែស្វាយព្រៃហ្នឹងទីរួមខេត្តតាកែវម៉េង ។

ភារិទ្ធ៖ អូ! ហើយពូចេញពីហ្នឹងមកទៅនៅឯណា?

សាន់៖ ចេញពីហ្នឹងមកទៅនៅឯភូមិល្អាត ឃុំពពេល ស្រុកត្រាំកក់ ។

ភារិទ្ធ៖ ហើយទៅនៅហ្នឹងធ្វើអីដែរ?

សាន់៖ អត់មានធ្វើអីទេ ធ្វើស្រែ ។

ភារិទ្ធ៖ នៅជាមួយគ្រួសារអីទាំងអស់តើអី?

សាន់៖ បាទ នៅជាមួយម៉ែឪ មានធ្វើអី ដល់ឆ្នាំ៧៣គេឲ្យមកនៅភូមិជ្រៃហ្នឹងវិញ ។

ភារិទ្ធ៖ នរណាគេឲ្យមកនៅ ខ្មែរក្រហមហេះ?

សាន់៖ ហ្នឹងហើយ គេរំដោះបានត្រឹមលាយបូរទៅលិច គេកាប់ត្រឹមវត្តលាយបូរយើងហ្នឹងណា៎ គេឲ្យធ្វើពីហ្នឹងទៅលិចវិញ ។

ភារិទ្ធ៖ ចុះកាលពីទៅនៅខាងភ៉ាហ្នឹងប្រធានភូមិឈ្មោះអីដែរ?

សាន់៖ កាលពីជំនាន់នោះមេ១០ខ្នង មេ៥០ខ្នង អត់ស្គាល់គេផងកាលហ្នឹង ។

ភារិទ្ធ៖ ចុះទៅនៅខាងល្អាត ប្រធានភូមិឈ្មោះអី?

សាន់៖ តាយន់ ។

ភារិទ្ធ៖ ប្រធានភូមិតែម្នាក់តើអីឬក៏មាននរណាទៀត?

សាន់៖ ៣នាក់ដែរ ។

ភារិទ្ធ៖ ឈ្មោះអីខ្លះ?

សាន់៖ ខ្ញុំស្គាល់តាយន់ហ្នឹងមួយ តែឥឡូវដឹងនៅអត់ អត់ដែលទាក់ទងទេ ។

ភារិទ្ធៈ អញ្ចឹងនៅហ្នឹងខ្មែរក្រហមកាន់កាប់ហើយហេះនៅល្ហាតហ្នឹង?

ស៊ាន់ៈ តែត្រឹមវត្តលាយបូរទៅទល់យើងភ្នំលិចណោះ ខ្មែរក្រហមទាំងអស់ អង្គតាសោមក៏គ្មានទ័ពលន់ណុលដែរ ។

ភារិទ្ធៈ ចុះនៅល្ហាតហ្នឹងបានរយៈពេលប៉ុន្មាន?

ស៊ាន់ៈ នៅល្ហាតហ្នឹងអត់បានគិតផង ប៉ុន្តែរយៈពេល....ខែធ្វើស្រែហ្នឹង យើងអត់បានធ្វើស្រែស្រុកគេមក ធ្វើស្រុកយើងនេះវិញណា៎ ប្រហែលជាមួយប្រាំងដែរហ្នឹង ។

ភារិទ្ធៈ អូ! ហើយមកនេះវិញ គាយន់ហ្នឹងឲ្យមក?

ស៊ាន់ៈ អត់ទេ គេបង្ខំឲ្យមកធ្វើស្រែ ដេញមកមុខនេះ ។

ភារិទ្ធៈ នរណាគេអ្នកបង្ខំមក?

ស៊ាន់ៈ កាលហ្នឹងគេមានបង្កើតឃុំលាយបូរហ្នឹង គេបង្កើតឃុំភូមិគេ ។

ភារិទ្ធៈ ប្រធានឃុំនរណាគេកាលហ្នឹង?

ស៊ាន់ៈ កាលហ្នឹងតាហូញ ។

ភារិទ្ធៈ ប្រធានភូមិតែម្នាក់ទេឬមាននរណាទៀត?

ស៊ាន់ៈ ទេ ប្រធានភូមិកាលហ្នឹងតាសែ ។

ភារិទ្ធៈ នៅរស់ដែរ?

ស៊ាន់ៈ នៅ ។

ភារិទ្ធៈ នៅឯណា?

ស៊ាន់ៈ ភូមិសីមា ហើយដល់ក្រោយមកមិនដឹងនរណាគេប្រធានភូមិទេ អត់ដឹងផង ។

ភារិទ្ធៈ ចុះពូនៅហ្នឹងរយៈពេលប៉ុន្មានដែរ?

ស៊ាន់ៈ មកនៅភូមិជ្រៃហ្នឹងឆ្នាំ៧៣ ដល់ឆ្នាំ៧៤ទើបគេចាប់ខ្ញុំទៅធ្វើខ្មែរក្រហមហ្នឹងម៉ង មិនមែនស្ម័គ្រចិត្តចូលឯណា គេចាប់ ខ្ញុំកំពុងឈឺនោមក្បែរដើមត្នោតអញ្ចឹងហេះ គេហៅទៅ គេឲ្យយកចានមួយស្លាបព្រាមួយទៅ ។

ភារិទ្ធៈ នរណាគេអ្នកចាប់?

ស៊ាន់ៈ នែ!....បូរ ។

ភារិទ្ធៈ បូរហ្នឹងធ្វើអី?

ស៊ាន់ៈ បូរហ្នឹងប្រធានឃុំវជនឃុំ ។

ភារិទ្ធៈ ហើយគេចាប់......?

ស៊ាន់ៈ គេហៅទៅ គេហៅទៅមុនដំបូង គេថាទៅនៅឃុំ

ភារិទ្ធៈ គេចង់យើងដែរអត់ទេ?

ស៊ាន់ៈ អត់ទេ គេហៅទៅឲ្យយើងទៅផ្ទះយើងយកចាន ស្លាបព្រាត្រឹមត្រូវហ្នឹងណា៎ ហើយដល់អញ្ចឹងទៅគេឲ្យ ហើយដល់ហាលល្ងាចចាំយើងទៅទៀត ដល់អញ្ចឹងនៅកន្លែងឃុំហ្នឹងគេឲ្យកាលហ្នឹងផ្ទះយើងនៅអញ្ចឹង ដ័យភ័ណ្ឌអីគេឲ្យរុះយកទៅធ្វើមន្ទីរពេទ្យ នៅកន្លែងទំនប់យើងខាងលិច ទំនប់ក្មេងប៉ែនយើងនេះ គេឲ្យធ្វើមន្ទីរពេទ្យអីហ្នឹងណា៎ ចេះតែនៅធ្វើអញ្ចឹងទៅ បានរយៈពេលមួយខែ គេឲ្យឈប់ ។

ភារិទ្ធៈ នរណាគេប្រធានមន្ទីរពេទ្យហ្នឹង?

ស៊ាន់ៈ កាលហ្នឹងមន្ត្រីឃុំមានតែ៣នាក់ទេ មិនដឹងជានរណាប្រធាន មួយណាអីទេកាលហ្នឹង ។

ភារិទ្ធៈ ឈ្មោះអី?

ស៊ាន់ៈ តែដឹងថាមិត្តណាវមួយនៅស្រែខ្វាវ បូហ្នឹងក៏នៅស្រែខ្វាវ ហើយពេទ្យហ្នឹងមិនដឹងជានរណាប្រធានទេ កាលហ្នឹងខ្ញុំអត់ដឹងដែរ មិនសូវចាប់អារម្មណ៍ទេ ដល់ក្រោយមកគេបញ្ជូនមក ទៅត្រៀមបាញ់ទាហានលន់ នល់ទៅ ។

ភារិទ្ធៈ នៅឯណា?

ស៊ាន់ៈ ថ្មក្រៀម មកស្នាក់នៅភូមិហ្នឹងដែរហេះ កាលហ្នឹងមានផ្ទះក្បឿងមួយនៅ ។

ភារិទ្ធៈ អូ! គ្នាប៉ុន្មាននាក់?

ស៊ាន់ៈ ឈ្លបឃុំមួយឃុំលាយបូរនៅមូលគ្នា ច្រើនដែរ បួនដប់ម្ភៃនាក់ទៅ ។

ភារិទ្ធៈ ចុះកាលហ្នឹងប្រធានពួឈ្លបហ្នឹងនរណាគេ?

ស៊ាន់ៈ ផុន ។

ភារិទ្ធៈ អូ! ផុន ។

ស៊ាន់ៈ នៅជាប់ជាមួយឌុច ជាមួយសាំងហ្នឹង រឿងខ្ញុំហ្នឹងឌុច, សាំងហ្នឹង នៅជាប់ជាមួយគ្នារហូតហ្នឹង ។

ភារិទ្ធៈ អូ! ចេញពីភូមិអីមកនៅជាមួយគ្នា?

ស៊ាន់ៈ ឌុច គេចេញមុន សាំងក៏ចេញមុនដែរ តែខ្ញុំចេញទៅក្រោយគេ តែជួបគ្នានៅឃុំហ្នឹងម៉ង ។

ភារិទ្ធៈ អូ! ជួបគ្នានៅឃុំ ឈ្លបដូចគ្នា?

ស៊ាន់ៈ បាទ! ឈ្លបដូចគ្នា ហើយដល់ហើយគេបញ្ជូនខ្ញុំទៅស្រុក ខ្ញុំទៅដល់ស្រុកក៏នឹកឃើញថា ហេ!បញ្ជូនទៅស្រុក ទៅវ៉ៃភ្នំពេញហើយ មិនដឹងជាយកខ្មោចទៅចោលឯណាទេ នាំគ្នារត់មួយសារទៅ ដល់រត់មួយសារទៅ គេយកទៅដាក់នៅកន្លែងនីរសាពេទ្យអង្គតាសោម កន្លែងដើមឈើទាលកន្លែងផ្ទះបងថេងយើង ខាងពន្ធដារ កន្លែងភូមិតាថេងហ្នឹង កន្លែងដើមឈើទាលជិតអង្គតាសោមហ្នឹង គេយកទៅដាក់នៅហ្នឹង ខ្ញុំរត់ទៅយកទៅដាក់ហ្នឹងគ្នា១០នាក់ គេឲ្យហូបអង្ករពាក់ប៉ុង

ហើយមើលទៅ យ៉ាប់យ៉ឺនពេក គេរើសតឡូវហ្អែងត្រូវនៅហ្នឹងឬមិននៅ បើមិននៅទៅសមរភូមិវិញ ហើយនាំគ្នាថា នរណាស៊ីយ៉ាងម៉េច បើអន្ករពាក់ប៉ុន្មានគ្នា១២នាក់ នាំគ្នាមកឈប់វិញ មកវ៉ៃទាហានលន់ នល់វិញ ។

ភារិទ្ធៈ ចុះទៅវ៉ៃទាហានលន់ នល់ហ្នឹង ឈដើងនៅឯណា?

ស៊ាន់ៈ ឈដើងនៅអូរស្វាយចេក ឈរដើងខ្ញុំឈរមិនទីងទេ មួយខែអញ្ចឹងគេដូរទៅអញ្ចឹងទៅ ទៅខ្សាច់សរទៅ ទៅខាងជើងតាកែវ ទៅតែអត់ដែលទៅត្បូងតាកែវ ទៅមកម្ដុំឬស្សីជ្រុំយើងមួយចំហៀងខាងនេះ ។

ភារិទ្ធៈ ចុះពូថាហៅមកស្រុកអីឆ្នាំណា?

ស៊ាន់ៈ មកស្រុកឆ្នាំ៧៥ ហើយហ្នឹង ជិតបែកហើយហ្នឹង ។

ភារិទ្ធៈ អូ! ជិតបែកហើយហេះ?

ស៊ាន់ៈ ជិតហើយ ។

ភារិទ្ធៈ ទៅនោះ ម៉េចបានជាពូដឹងថាគេប្រុងបញ្ជូនមក...វិញ?

ស៊ាន់ៈ ខ្ញុំគេបញ្ជូនទៅភាគ មានតែគេបញ្ជូនទៅវ៉ៃភ្នំពេញ តែឡើងទៅភាគគេបញ្ជូនទៅហើយ គេដឹកឡានទៅម៉ង គេមិនមែនមករៀបទ័ពនៅតាកែវអត់ទេ គេរៀបទ័ពខាងកងពលណោះ គេដឹកទៅតែម្ដងហើយដល់គេបំពាក់អាវុធនៅវត្តពន្លឺហ្នឹងខ្ញុំក៏អត់មាននេះ នាំគ្នារត់តែម្ដង រត់ហ្នឹងមិនមែនរត់លេងធេងទេ ជួបនៅឯណាបាញ់ចោលនៅហ្នឹង ហើយខ្ញុំចេះតែរត់ទៅដេកនៅព្រៃស្ទឹងណោះ ម៉ែឪយកបាយឲ្យស៊ីនៅព្រៃស្ទឹងណោះ ហើយព្រៃស្ទឹងកាលហ្នឹងមិនមែនព្រៃដូចរាល់ថ្ងៃឯណា ព្រៃអត់ហ៊ានចូលទេ ឆ្កែចចករហឹងណាំ ។

ភារិទ្ធៈ រត់ប៉ុន្មាននាក់?

ស៊ាន់ៈ រត់គ្នាហ្នឹង អាខុម, អាវ៉ាន់ អាខុមធ្វើពាងនៅអន្កនរាយណ៍ខាងត្បូងនេះ ។

ភារិទ្ធៈ នៅរស់តើអី?

ស៊ាន់ៈ នៅ ហើយហ្នឹងតាម៉ននៅឪុបលោក តានេះអន្កតាសោម ឪុបលោកសង្ឃរាជវត្តអន្កតាសោមនេះស្គាល់ទេ?

ភារិទ្ធៈ អត់ ។

ស៊ាន់ៈ តាម៉នហ្នឹងមួយ ឃើញនៅ៤នាក់ដែរមួយស្រករហ្នឹង ក្រៅពីហ្នឹងងាប់អស់ហើយ ទៅបូព៌ាងាប់អស់ហើយ ហើយដល់ក្រោយមកហ្នឹង គេហៅ ត្រចៀកខ្ញុំស្នាមទល់តឡូវនេះ ថាឯងប៉ិនរត់ដុតហ្នឹងភ្លើងបារី គ្នាឯងហ្នឹងណាំ តែអាប៉េះហ្នឹងស្លាប់បាត់ហើយ ទៅបូព៌ា ហើយដល់ហើយគេបញ្ជូនខ្ញុំមក ខ្ញុំក៏នឹកឃើញថា ខ្ញុំរត់ទៅព្រៃទទឹងយូរពេកជិតមួយខែ ពិបាកលំបិនដល់ម៉ែឪខ្ញុំពេក

ខ្ញុំក៏មកផ្ទះនេះវិញ មកផ្ទះនេះវិញ គ្រាន់តែមកដល់ផ្ទះគេនៅហ្នឹងផ្ទះ ដល់ហើយគេហៅខ្ញុំមកឈ្លបវិញ ច្រើនគន្ទាក់ណាស់ខ្ញុំទំរាំតែបានធ្វើហ្នឹង ។

ភារិទ្ធ: មកឈ្លបហើយទៅវ៉ៃតាកែវទៀត?

ស៊ាន់: មកឈ្លបហើយទៅត្រៀមវ៉ៃតាកែវទៀត មួយសារទៀត ។

ភារិទ្ធ: ទៅប៉ុន្មានខែទើបវ៉ៃតាកែវបែក?

ស៊ាន់: យី! ទំរាំតែបែកយូរដែរ វាចូលខែ៣ ខែ៤ ខែ៥ហើយ បែកតាកែវខែ៥ ។

ភារិទ្ធ: ខែ ៤ ឆ្នាំ៧៥ ។

ស៊ាន់: អញ្ចឹងហើយខែ៤ អញ្ចឹងខ្ញុំបែកតាកែវហ្នឹង ខ្ញុំនៅនេះណោះ ភូមិក្តុលអញ្ចុងណោះ ទៅត្រៀមខាងជើងអន្លង់ធ្លកកាលហ្នឹងគេនៅអន្លង់ធ្លកណោ៎ះ កាលពីជំនាន់លន់ នល់ ។

ភារិទ្ធ: ហ្នឹងកាលបញ្ជូនកាលហ្នឹងអ្នកដែលឈ្លបទាំងប៉ុន្មាន?

ស៊ាន់: កាលហ្នឹងខ្ញុំឡើងទៅស្រុក គេនៅឈ្លប សាំងគេនៅឈ្លបឃុំណា ខ្ញុំឡើងទៅស្រុកហើយ ឡើងទៅស្រុកហ្នឹងគ្នាមួយឃុំលាយបូរហ្នឹង គេធ្វើពិធីជប់លៀងមួយហើយ បានគេបញ្ជូនទៅស្រុកកាលហ្នឹង ប្រជាជនគេជឿ ជំនឿលើទ័ព ។

ភារិទ្ធ: ចុះស្រុកហ្នឹងនរណាគេ?

ស៊ាន់: តាសឿន ។

ភារិទ្ធ: តែម្នាក់ហ្នឹងទេ?

ស៊ាន់: ទេកាលហ្នឹងដូចជាមិនមែនតាសឿនទេ តែប្រជាជនរៀងប្រជាជនទូទាំងស្រុកខ្ញុំអត់ដឹងទេណោ៎ះ តែខ្ញុំដឹងតែប្រធានយោធាស្រុក ខ្ញុំដឹងតែប៉ុណ្ណឹង ដឹងតែតាសឿនហ្នឹងមួយ គេហៅថាតាសឿនរបូតខោៗ នៅត្រពាំងធំហ្នឹងណា អន្លង់រាយណ៍ហ្នឹងណា ។

សុជាតិ: ម៉េចបានជាគេហៅគាត់អញ្ចឹង?

ស៊ាន់: កាលហ្នឹងទាហានចុះបាញ់នៅខាងត្បូងឬស្សីជ្រុំហ្នឹង ក៏រត់ទៅគាស់គុម្ពឬស្សី របូតខោនៅគុម្ពឬស្សីហ្នឹងណោ៎ះ ដល់ហើយគេហៅតាសឿនរបូតខោទៅអញ្ចឹង ។ ហើយដល់បែកតាកែវហ្នឹងក៏ខ្ញុំអត់ដឹងដែរ តែគេបញ្ជូនទៅធ្វើបុណ្យនៅវត្តប្រភ្នំ ។

ភារិទ្ធ: បុណ្យអី?

ស៊ាន់: បុណ្យជប់លៀងទ័ពហ្នឹង គេធ្វើបុណ្យមហាហូបគេហ្នឹង គេឲ្យកងទ័ពតំបន់ស្រុកអី តែស្រុកទៅហ្នឹងអត់បានមហាហូបគេទេ បានតែគេទ័ពតំបន់ ទ័ពពិសេសគេទេ ដល់ទ័ពស្រុកនៅលើសាលាឆាន់លោកវត្តប្រភ្នំហ្នឹង នៅលើសាលាឆាន់ហ្នឹងបាយតាមស្រុកគេទទួល ស្រុកត្រាំកក់យើងគេទទួលនៅស្រុក ត្រាំកក់ទៅណោ៎ះ ។

ភារិទ្ធៈ បាទ!

ស៊ាន់ៈ ហើយដល់គេគេទទួលនៅស្រុកគេ ហើយដល់ពេលតំបន់គេមហាហូបគេ ដល់ចប់ហ្នឹងខ្ញុំក៏ឈឺ ឈឺមកហ្នឹងគេដាក់អង្រឹងសែងរហូត គេមកជប់លៀងនៅហ្នឹងយើងហ្នឹង ។

ភារិទ្ធៈ ឈឺអីកាលហ្នឹង?

ស៊ាន់ៈ គ្រុនចាញ់កាលហ្នឹង គ្រុនចូលជិត៣ខែ ដល់តែអញ្ចឹងខ្ញុំក៏គេថាមហាហូបតាមស្រុក គេហៅមកជប់លៀងនៅអគ្គរការយើងនេះ គេធ្វើមហាហូបត្រង់កន្លែងផ្សារអគ្គរការយើងសព្វថ្ងៃនេះ ធ្វើមហាហូបនៅហ្នឹងមួយវគ្គទៀត ដល់តែអញ្ចឹងគេចែកគាមកង ចែកគាមកងខ្ញុំអត់ព្រមចូលកងទេ ខ្ញុំថាមកផ្ទះ គេរៀបកងហើយៗ មួយកង៥០នាក់ៗ គេបែងចែក ខ្លះទៅធ្វើផ្លូវរថភ្លើង ខ្លះធ្វើផ្លូវជាតិទៅណា កាលពីបែកហើយហ្នឹង អត់មានបញ្ហាខាងទ័ពការពារអីទេពីព្រោះគេរើសកម្លាំងការពារហើយអស់ ដល់ខ្ញុំនៅសល់៣នាក់ កង៥០អីហ្នឹងមកតាកែវនេះវិញ មកតាកែវវិញគេឲ្យយាម កាលហ្នឹងប្រជាជនអត់ទាន់ចូលដល់ទេ ត្រឹមភូមិសីមាខាងកើតនេះ គេឲ្យនៅយាមត្រឹមហ្នឹងអត់ឲ្យប្រជាជនចូលព្រោះអីអត់ទាន់ដោះមីន ទាល់តែបែកអស់ ក៏នាំគ្នានៅត្រឹមហ្នឹងសិនដល់តែទំរាំចូលទៅ ដល់ហើយទៅដល់អគ្គធ្លក ទៅដល់គេឲ្យបានគ្នាច្រើនហើយបានចូល៥០នាក់លីចបរូបដីមួយៗម្នាក់ កាប់ដីតាម គាស់ដាំពោត ដាំដំឡូងហ្នឹងណា ហើយនាំគ្នាបរទេះគោមិនមែនបរគោទេ មិនមែនបរគោទេ បរមនុស្ស ទៅដឹកអាចម៍គោតាកែវមកដាំពោត ដាំដំឡូង ។

ភារិទ្ធៈ បរមនុស្សម៉េច?

ស៊ាន់ៈ ហើយគោហ្នឹងតម្រៀបគ្នាកាប់ម៉ង អត់មានភ្ជួរគោទេ ។

សុជាតិៈ ឲ្យមនុស្សបរ?

ស៊ាន់ៈ មនុស្សបរទេះទៅដឹកអាចម៍នៅតាកែវណោះ មួយរទេះ៦នាក់ៗអញ្ចឹងម៉ង ហើយតម្រៀបគ្នាកាប់តើដីភូមិប្របៗផ្លូវជាតិហ្នឹង កាប់ចបកាប់ម៉ងណា៎ អត់មានភ្ជួរមានរាស់អីអត់ទេ ទុកកាំភ្លើងហើយតម្រៀបគ្នាកាប់ម៉ង ហើយដល់ក្រោយមក៏គេបញ្ជូនខ្ញុំទៅដីរីរមៀល កាលហ្នឹងគេថាព្រំ សាន់ក្បត់ខាងទ័ពព្រំ សាន់ក្បត់ ។

ភារិទ្ធៈ ឆ្នាំប៉ុន្មានពូ?

ស៊ាន់ៈ ឆ្នាំ៧៥ហើយ ។

សុជាតិៈ បែកភ្នំពេញនៅ?

ស៊ាន់ៈ បែកហើយ ដូចជាខ្ទង់ខែ៧ខែ៨ហ្នឹងតាមមើល ។

ភារិទ្ធៈ ព្រំ សាន់ហ្នឹងស្អីគេ?

សាន់ៈ ព្រំ សាន់ហ្នឹងអញោះ កាលមុនគាត់ហ្នឹងមេខ្មែរក្រហមដែរ តែលឺគេនិយាយ ខ្ញុំក៏មិនបានចាំច្បាស់ដែរ គាត់ថាមេខ្មែរក្រហមដែរ ដល់ហើយក៏គាត់មានបក្សពួកគាត់រត់ឡើងភ្នំ គេថាធ្វើគណបក្សប្រឆាំងហ្នឹងណា កាលហ្នឹងជាមួយតាគាវ តាអឺ គាត់មេខ្មែរក្រហមដែរ គាត់គំបន់ណ៎ កាលហ្នឹងគាត់អ្នកធំៗគេក្បត់គ្នា ក៏គេបញ្ជូនខ្ញុំនៅខាងស្រុកហ្នឹង ដល់ហើយខ្ញុំអត់ដឹងទេ ដល់ហើយ ហេះ! ពួកហ្នឹងគិត ឡើងទៅក្រាំងតាចាន់ ខ្ញុំក៏មិនដឹងថាក្រាំងតាចាន់ហ្នឹងឯណាទេ ។

ភារិទ្ធៈ នរណាគេជាអ្នកនិយាយ?

សាន់ៈ ប្រធានកងហ្នឹងណ៎ ។

ភារិទ្ធៈ ប្រធានកងហ្នឹងឈ្មោះអី?

សាន់ៈ ឈ្មោះកាលហ្នឹង ឈ្មោះ ភីម ។

ភារិទ្ធៈ កងឈ្លបហេះ?

សាន់ៈ ស្រុក ។

ភារិទ្ធៈ ប្រធានកងឈ្លបស្រុកហេះ?

សាន់ៈ បាទ!

ភារិទ្ធៈ អូ!

សាន់ៈ តាភីមថា ហេ! ដក៦នាក់ហ្នឹងមកស្រុកហើយ ឲ្យទៅនៅយាមក្រាំងតាចាន់ ហើយខ្ញុំមកដល់ក្រាំងតាចាន់ គ្នាខ្ញុំ៦នាក់ហ្នឹងមកដល់គ្មានទៅស៊ីអីទេ ។

ភារិទ្ធៈ នរណាខ្លះ?

សាន់ៈ ឌុច ស៊ីម សាំង ហើយ អ្នក អ៊ួកហ្នឹងនៅបសែតណោះ ហ្នឹងទូច ។

ភារិទ្ធៈ អ្នកហ្នឹងនៅរស់ដែរ?

សាន់ៈ មិនដឹងរស់ ឬស្លាប់អត់ដែលជួបគ្នារលីង តាំងពី៧៩មកដល់សព្វថ្ងៃជួបតែឌុចហ្នឹងទេ ។

ភារិទ្ធៈ ឌុចតូច ឬធំ?

សាន់ៈ ឌុចតូចណ៎ ។

ភារិទ្ធៈ ឥឡូវ៦នាក់ហ្នឹងឈ្មោះអីខ្លះ?

សាន់ៈ ឌុច ស៊ីម សាំង ទូច អ៊ួក ហើយហ្នឹងខ្ញុំ ដល់ហើយមកនៅហ្នឹងក៏គេគ្មានបានធ្វើការអីដែរ ស៊ីបាយហើយដេក អត់មានធ្វើការអីទេ រយៈពេលជិតមួយឆ្នាំ ពួកខ្ញុំមកដល់ហ្នឹងគេឲ្យតែធ្វើស្រែយាមទេ មួយយប់យាម២ម៉ោង អត់មាននាទីអីទេ ។

ភារិទ្ធៈ នរណាគេប្រធាន៦នាក់ហ្នឹង?

សាន់៖ ៦នាក់ហ្នឹងអត់មានប្រធានទេ យើងមករស់នៅជាមួយគេ ដូចយុទ្ធជនអញ្ចឹងណា៎ មកពីគេមកគ្រាន់តែនៅជាមួយគេ គេក្តាប់យើងហើយ ។

ភារិទ្ធ៖ កាលហ្នឹងឆ្នាំប៉ុន្មានពូ?

សាន់៖ ឆ្នាំ ៧៥ ជិត៧៦ហើយ ។

ភារិទ្ធ៖ ចុងឆ្នាំ៧៥?

សាន់៖ បាទ! ចុង៧៥ ។

ភារិទ្ធ៖ ហើយដល់ពេលមកគេឲ្យធ្វើអី?

សាន់៖ អត់មានធ្វើអីទេ គេឲ្យនៅតែហ្នឹងជិតមួយឆ្នាំ ៧៦ហ្នឹងគេគ្រាន់តែប្រើ ដល់ខែធ្វើស្រែអញ្ចឹងគេឲ្យ យើងស្ទូងយើងដកអី យប់ឡើងដេកយាមទៅ គេដេកទៅណា៎ ។

ភារិទ្ធ៖ ចុះពេលដែលពូមកហ្នឹង ពូកាលហ្នឹងក្រាំងតាចាន់ហ្នឹងមានអ្នកទោសមានអីដែរ?

សាន់៖ កាលពីមកដល់ហ្នឹងមាន ។

ភារិទ្ធ៖ ច្រើនដែរអត់ទេ?

សាន់៖ ច្រើនដែរ ៣០-៤០នាក់អញ្ចឹងដែរពេលដែលខ្ញុំមកដល់ហ្នឹង ចេះតែចូលតៗអញ្ចឹងមានដល់មួយរយ-ពីររយអញ្ចឹងទៅណា៎ ។

ភារិទ្ធ៖ បាទ! អ្នកទោសគេបញ្ជូនមកពីណាវិញ?

សាន់៖ តាមឃុំ ថាក្បត់អញ្ចេះ ក្បត់អញ្ចោះ ឃុំគេបញ្ជូនទៅណា៎ ហើយសួរចម្លើយសួរអី ធ្វើរបាយការណ៍ ក៏គេរាយការណ៍ទៅ ។

ភារិទ្ធ៖ នរណាគេអ្នកសួរចម្លើយ នរណាគេអ្នកធ្វើរបាយការណ៍?

សាន់៖ អាន់ ។

ភារិទ្ធ៖ អាន់ អ្នកសួរចម្លើយ?

សាន់៖ បាទ ។

ភារិទ្ធ៖ នរណាគេអ្នកធ្វើរបាយការណ៍?

សាន់៖ អាន់ ហើយ ចេង ពេញ ។

ភារិទ្ធ៖ ចុះឌុចធំ?

សាន់៖ ឌុចធំអ្នកសួរចម្លើយដែរ គ្នាគេ៣-៤នាក់ គាត់ប្រធានយុវជនស្រុក ។

ភារិទ្ធ៖ ចុះមានស្គាល់ឈ្មោះដាំ ទេ?

សាន់៖ តាដាំ មិនដឹងជាគាត់នៅហ្នឹងតាំងពីឆ្នាំណាមក ខ្ញុំអត់ដឹងដែរ ប៉ុន្តែដល់ពេលគាត់ខូចជាមួយកូនប្រពន្ធគេ ។

ភារិទ្ធៈ ខូចនៅឯណា?

ស៊ាន់ៈ ខូចនៅជិតក្រាំងតាចាន់ហ្នឹង ដល់ហើយក៏គេដាក់គុកគាត់នៅហ្នឹងដែរទៅ ។

ភារិទ្ធៈ នឹងឆ្នាំប៉ុន្មានពេលដែលគាត់ខូចហ្នឹង?

ស៊ាន់ៈ កាលពីខ្ញុំទៅឃើញគាត់នៅហ្នឹងហើយ ខ្ញុំអត់មានដឹងដែរ ។

ភារិទ្ធៈ តែកាលហ្នឹងគាត់ខូចនៅ?

ស៊ាន់ៈ គាត់ខូចរួចហើយ ខ្ញុំទៅឃើញតែគាត់នៅតែហ្នឹង មិនដឹងពីឆ្នាំណាមកក៏អត់ដឹង ហើយខ្ញុំក៏មិនសួរដេញដោលគាត់ ។

ភារិទ្ធៈ គាត់នៅហ្នឹងគេឃុំឃាំងគាត់ដែរអត់ទេ?

ស៊ាន់ៈ ឃុំឃាំង គាត់យប់ឡើងគេដាក់ក្នុងគុក ថ្ងៃគេឡើងគេឲ្យចេញជួយធ្វើការងារអញ្ចឹងទៅណា៎ ហើយថ្ងៃឡើងគេឲ្យពូមើលគោ មើលក្របីអញ្ចឹងទៅណា៎ ។

សុកគៀនៈ ពូពេលសួរចម្លើយហ្នឹង គេធ្វើរបាយការណ៍ គេសរសេរអក្សរគេធ្វើយ៉ាងម៉េចពូ?

ស៊ាន់ៈ សរសេរអក្សរហើយវាយអង្គុលីលេខ ។

សុកគៀនៈ នរណាគេជាអ្នកវាយអង្គុលីលេខ?

ស៊ាន់ៈ អ្នកវាយអង្គុលីលេខឌុចធំយើងហ្នឹង អ្នកសរសេរគ្នាគេ៣-៤នាក់ហ្នឹង ។

ភារិទ្ធៈ មុនហ្នឹងពូទៅដល់ អ្នកដែលកាន់នៅហ្នឹងម៉ងប៉ុន្មាននាក់?

ស៊ាន់ៈ ៦នាក់ ខ្ញុំដឹងតែឌុច, ចេង, អាន់, ឈៀង, មឿន, ពេញ, ពេញហ្នឹងក្រោយទេ ៦នាក់តាពេញហ្នឹង ទើបតែដកចូលឆ្នាំ៧៧-៧៨ហ្នឹងទេ ។

ភារិទ្ធៈ អូ! ពេញចូលក្រោយពូដងអញ្ចឹង?

ស៊ាន់ៈ ក្រោយ កាលហ្នឹងតាពេញហ្នឹង គាត់ប្រធានសហករណ៍នៅភូមិអីទេខាងត្បូងត្រពាំងធំ, បឹងប្រិយ៍ ឬ អីទេ នៅបៀត១៦០ហ្នឹង ។

ភារិទ្ធៈ ១៦០ហ្នឹងអីគេ?

ស៊ាន់ៈ កន្លែងដាក់សម្ភារៈដាក់គ្រាប់ ឬសម្ភារៈដូចជាម៉ូតូអីហ្នឹង កាលពីបែកភ្នំពេញដឹកយកទៅទុកនៅហ្នឹង

ភារិទ្ធៈ នរណាគេអ្នកកាន់នៅ១៦០ហ្នឹង?

ស៊ាន់ៈ អត់ស្គាល់ទេ របងគេពទ្ធដីមួយគីឡូ៤ជ្រុងអត់ដែលចូលផង ។

ភារិទ្ធៈ ចុះពូនៅហ្នឹងអ្នកទោសអីមានដោះលែងវិញទេ?

ស៊ាន់ៈ លែងច្រើនដែរដូចជាទោសលួចមាន់ ទោសដូចចាប់រំលោភនារីអីហ្នឹងណា ឃើញគេលែងច្រើនដែរ ហើយដូចជាចាប់ច្រឡំ ហ្នឹងឃើញលែង ហើយបើទោសដូចថាពីនេះទៅគេរាយការណ៍ធ្ងន់ៗទៅអត់ មានលែងទេ ។

ភារិទ្ធៈ	គេមានអ្នកទោសនៅហ្នឹង គេមានសួរចម្លើយ មានវ៉ៃធ្វើទារុណកម្មអីដែរអត់ទេ?

ស៊ាន់ៈ	វ៉ៃ ។

ភារិទ្ធៈ	នរណាគេអ្នកសួរចម្លើយ អ្នកវ៉ៃអ្នកអី?

ស៊ាន់ៈ	មានតែតាអាន់, ពេញ, ចេង, ឌុចហ្នឹង ៤នាក់ហ្នឹង ។

ភារិទ្ធៈ	ចុះអ្នកទោសដែលគេយកទៅសម្លាប់ហ្នឹង នរណាគេអ្នកសម្លាប់អ្នកអី?

ស៊ាន់ៈ	អ្នកសម្លាប់តែបក្សជនគេ៦រូបហ្នឹង,

ភារិទ្ធៈ	អូ!

ស៊ាន់ៈ	៦រូបគេនៅមុនហ្នឹង យើងគ្រាន់តែមាននាទីយាមទេ ក្រោយៗមកទើបមកស្រុកវិញហ្នឹង បើសម្លាប់ គេលែងហ៊ានមកហើយ ។

ភារិទ្ធៈ	ចុះម៉េចបានជាពូដឹងថាអ្នកហ្នឹងសម្លាប់គេ ៦នាក់ហ្នឹង?

ស៊ាន់ៈ	បានដឹង ព្រោះអ្នកទោសសម្លាប់នៅហ្នឹង មានយកទៅឯណា?

ភារិទ្ធៈ	ពូឃើញហីអី?

ស៊ាន់ៈ	បញ្ជូនទៅវាគិចណា បញ្ជូនទៅដាក់ឡានទៅមិនដឹងជាទៅឯណា ដាក់ឡានទៅ គេមិនប្រាប់ថាសម្លាប់កន្លែងនេះ កន្លែងនោះវាអត់ណា៎ បើមិនបញ្ជូនគ្មានកន្លែងកប់ទេ កន្លែងហ្នឹង ។

ភារិទ្ធៈ	អូ! មានបញ្ជូនចេញដែរ?

ស៊ាន់ៈ	បញ្ជូនចេញ ។

ភារិទ្ធៈ	ចុះអ្នកដែលសម្លាប់នៅកន្លែងហ្នឹងមានច្រើនដែរ?

ស៊ាន់ៈ	៦នាក់គ្នាគេហ្នឹង ។

ភារិទ្ធៈ	អញ្ចឹងអ្នកទោសមានបញ្ជូនទៅណាដែរមានដឹងទេ?

ស៊ាន់ៈ	បញ្ជូនចេញគេថាទៅ២០៤ ។

ភារិទ្ធៈ	អូ!

ស៊ាន់ៈ	២០៤ហ្នឹងក៏ខ្ញុំមិនដឹងថានៅឯណា ខ្ញុំអត់ដឹងដែរ ។

ភារិទ្ធៈ	អញ្ចឹងការកាលពី៧៦ហ្នឹង ២០៤ហ្នឹងទៅតែមានការឃុំឃាំងមនុស្សដែរ?

ស៊ាន់ៈ	មិនដឹង តែមិនដឹងជា២០៤ហ្នឹងនៅឯណា តែលឺប្រជាជននៅព្រៃក្តួច លឺប្រជាជនថានៅព្រៃដាច់ខាងលិចព្រៃក្តួចណោះណា៎ ឯអូតចោទណោះ លឺប្រជាជនថាអញ្ចឹងដែរ តែខ្ញុំអត់ដែលទៅ ។

ភារិទ្ធៈ	នរណាគេអ្នកនិយាយថាទៅ២០៤?

ស៊ាន់ៈ	ប្រជាជននៅស្រុកព្រៃក្តួចហ្នឹង ដឹងស្រុក២០៤ហ្នឹងម៉ង ។

ភារិទ្ធៈ អត់ទេ ខ្ញុំចង់សួរពូថា បញ្ជូនអ្នកទោសទៅហ្នឹង ដូចថាសម្លាប់នៅហ្នឹងដាក់មិនអស់ទេហើយដល់ពេលបញ្ជូនចេញ ។

ស៊ាន់ៈ គេគណៈកម្មការគេបញ្ជូនចេញដាក់ឡានទៅ ប្រធានគេហ្នឹង ។

ភារិទ្ធៈ គេប្រាប់ថាបញ្ជូនទៅ២០៨?

ស៊ាន់ៈ បាទ! ដាក់ឡានចេញទៅណា ដាក់ខ្នោះចងដាក់ឡានទៅ ។

ភារិទ្ធៈ អ្នកទោសហ្នឹងមានស្រី មានប្រុស មានក្មេងអីទេ?

ស៊ាន់ៈ មានតែ តែអត់សូវមានក្មេងទេ មានតែចាស់ៗ ដូចយើងជំនាន់នេះយើងធ្វើ PM ប៉ូលីសទាហាន អីហ្នឹងណា មិនសូវមានស្រីទេ ច្រើនតែប្រុស ស្រីតិចណាស់ ។

ភារិទ្ធៈ ស្រីប្រហែលជាប៉ុន្មាននាក់?

ស៊ាន់ៈ ស្រីតាមខ្ញុំនៅហ្នឹងមិនដល់១០០ទេ ៣០-៤០អីហ្នឹង ។

ភារិទ្ធៈ មានក្មេងមានចាស់ដែរ?

ស៊ាន់ៈ អត់សូវមានក្មេងទេ ក្មេងយ៉ាងច្រើន៤-៥នាក់ បើទាំងគ្រួសារៗគេដាក់ឡានទៅ មិនដឹងទៅឯណា

ភារិទ្ធៈ ចុះអ្នកទោសដែលគេបញ្ជូនមកហ្នឹងញឹកញាប់ដែរអត់ទេ?

ស៊ាន់ៈ មួយខែ៤-៥នាក់អញ្ចឹងទៅ តាមឃុំគេមានទោសអីនៅឃុំ របាយការណ៍គេទៅ គេរាយការណ៍គេចាប់បញ្ជូនមកណា ។

ភារិទ្ធៈ ចុះអ្នកទោសនៅហ្នឹងគេដូចថាមានឃុំប៉ុន្មានអាគារដែរ ហើយការឃុំឃាំងគេ គេឃុំយ៉ាងម៉េចអីយ៉ាងម៉េច?

ស៊ាន់ៈ ឃុំឃាំងគេមាន៣អាគារ ឃុំឃាំងគេដាក់ខ្នោះជើង ដៃ ខ្នោះAutomatic ។

ភារិទ្ធៈ ដាក់ម៉េចទៅ?

ស៊ាន់ៈ ជើងដាក់ទាំងពីរម៉ង ។

ភារិទ្ធៈ Automatic យ៉ាងម៉េច?

ស៊ាន់ៈ ខ្នោះ Automatic យើងអាខ្នោះប៉ូលីស PM យើងសព្វថ្ងៃហ្នឹង ដាក់ជាប់គ្នាហ្នឹង ។

ភារិទ្ធៈ អូ! អាខ្នោះដៃហ្នឹងហេះ?

ស៊ាន់ៈ ហ្នឹងហើយ ខ្នោះដៃយើងដាក់ជាប់គ្នា តគ្នា ទុកតែម្នាងៗហូបបាយទៅណា ។

ភារិទ្ធៈ ចុះខ្នោះជើង?

ស៊ាន់ៈ ខ្នោះជើង ស៊ីករនុកដែក អាកងហ្នឹងស៊ីកក្រវិលពីក្រោមហ្នឹង អាដែកសរសៃហ្នឹងស៊ីកក្រវិលពីក្រោម ហើយចាក់សោរអាក្បាលរនុកហ្នឹង ។

ភារិទ្ធៈ នរណាគេអ្នករៀបឃុំអ្នកទោសដាក់ខ្នោះដាក់អីអញ្ចឹង?

ស៊ាន់:	វាចែកវែនគ្នា ១-២ម៉ោងអញ្ចឹង ។ អត់ទេរៀបមួយខ្សែៗ គេសួរចម្លើយគេអ្នករៀប គេ៦នាក់ហ្នឹងគេរៀបតាមលេខរៀងគេហ្នឹង នរណាសួរចម្លើយហើយដាក់ម្នាងអញ្ចឹងទៅៗ ។

Cassette 1
Side B

ស៊ាន់:	........សម្លាប់ក្លាមអត់ទេ ទាល់តែសរសេរជាក្រដាសសំបុត្រអីហើយបញ្ជូនមកតាម៉ុកហើយបានតាម៉ុកមិនសូវមាន តាម៉ុកច្រើនតែគូសរហូតអញ្ចឹងម៉ង អត់មានសូវមានគូសមួយៗអញ្ចឹងអត់ទេ គូសទាំងមូលម៉ង ។

ភារិទ្ធ:	ម៉េចបានជាពូដឹងថាបញ្ជូនមកតាម៉ុក?

ស៊ាន់:	ខ្ញុំអ្នករត់សំបុត្រ ។

ភារិទ្ធ:	អូ! អូ! គូសហ្នឹងមានន័យថាម៉េច?

ស៊ាន់:	គូសហ្នឹងមានន័យថាសម្លាប់ចោលម៉ង ឲ្យតែគូសក្រហមសម្លាប់ចោលម៉ង អត់មានទុកទេ ។

ភារិទ្ធ:	អ្នកហ្នឹងខុសអីបើតាមពូមើលទៅ ។

ស៊ាន់:	តាមខ្ញុំពិនិត្យតាមដានមើល វាគ្មានខុសអីទេ បងប្រពន្ធខ្ញុំហ្នឹងក៏អញ្ចឹងដែរ ។ បងប្រពន្ធខ្ញុំខូចជាមួយបងថ្លៃ ហើយយកទៅគេថាបងបងស៊ាន់ឯងមកណោះ ហើយខ្ញុំសួររកមើល សួរចុះសួរឡើងដល់ហើយទៅដល់ គ្មានអីផង ខូចគ្នារាយការណ៍ អាប្រុសកោរក្បាលខ្វែងជើងក្អែកអញ្ចឹងណា៎ កោរហើយគេបញ្ជូនទៅហ្នឹងដែរទៅ ទៅហ្នឹងតែទោសអញ្ចឹងៗរូចណា៎ មានរួចខ្លះ ហើយទោសមួយទៀត យើងធ្វើទាហានជិនាន់លន់ណុល ដូចពាក់សក្តិ៥ សក្តិ៣ សក្តិ២ធ្វើ PM អីហ្នឹងណា៎ គេថាក្បត់ អញ្ចេះក្បត់អញ្ចោះ ដូចជាទៅកំពុងយោលទម្លាក់អង្ករក្នុងទឹកចោលអញ្ចឹងទៅណា៎ បែកចាន ក្រឡាប់ទូកគេ លិចទូកគេអីហ្នឹង គេបញ្ជូនទៅហើយ អញ្ចឹងណា៎តាមឃុំណា៎ បើតាមស្រុកនោះបើគ្មាន អ្នកធ្វើឃុំធ្វើរបាយការណ៍ឡើងក៏គេគ្មានដឹងអីដែរ ឃុំបញ្ជូនទៅវិញ ។

ភារិទ្ធ:	អញ្ចឹងពូរត់សំបុត្រទៅដល់តាម៉ុកដែរ?

ស៊ាន់:	ខ្ញុំទៅត្រឹមស្រុក កាលហ្នឹងតាសាន នៅខាងស្រុក ។

ភារិទ្ធ:	ចុះម៉េចបានជាពូឃើញសំបុត្រដែលតាម៉ុកគាត់ដាក់បញ្ជា?

ស៊ាន់:	បានឃើញព្រោះសំបុត្រហ្នឹងវិលត្រលុបទៅវិញ ពីស្រុកទៅគេយកទៅឲ្យដល់នោះវិញ បានឃើញគេគូសក្រហមហ្នឹង ។

សុកគឿន:	ដែលបញ្ជូនសំបុត្រមកទុកមួយអី អត់សម្លាប់ណា៎ មានទេ?

ស៊ាន់:	អត់ទេ ។

សុកគឿនៈ តែបញ្ជូនមកដឹងតែសម្លាប់ចោលហើយ?

ស៊ាន់ៈ ដឹងតែសម្លាប់ហើយ ។

ភារិទ្ធៈ អញ្ចឹងការសម្លាប់ហ្នឹងទាល់តែមានការបញ្ជាពីលើមក?

ស៊ាន់ៈ ទាល់តែបញ្ជាពីលើ អត់មានយើងសម្លាប់ទៅអីបានទេ ធ្វើរបាយការណ៍ឡើងលើហើយបាន

ភារិទ្ធៈ អ្នកដែលបញ្ជា អ្នកគូសហ្នឹងមានដាក់ឈ្មោះតាម៉ុកម៉ងឬយ៉ាងម៉េច?

ស៊ាន់ៈ មិនដឹង ខ្ញុំមិនដែលមើលខ្លួនសំបុត្រផង ។

ភារិទ្ធៈ ប៉ុន្តែម៉េចបានដឹងថាតាម៉ុក?

ស៊ាន់ៈ ដឹងថាក្រដាសហ្នឹងគេថារបាយការណ៍ ឧទាហរណ៍ថា៣០នាក់ ៤០នាក់អញ្ចឹងណា៎ គេគូសចោល ខ្ញុំ មើលសំបុត្រហ្នឹងឃើញគូសហ្នឹងម៉ង ។

ភារិទ្ធៈ តែម៉េចបានជាពូហ៊ានសន្និដ្ឋានថា តាម៉ុក?

ស៊ាន់ៈ ចុះសំបុត្រហ្នឹងគេថា បញ្ជូនទៅតាម៉ុក ។

ភារិទ្ធៈ អូ!

ស៊ាន់ៈ គេថាអញ្ចឹង កាលហ្នឹងគេមិនហៅថាតាម៉ុកទេ គេហៅថាតា១៥ ។

ភារិទ្ធៈ ពូរត់សំបុត្រហ្នឹងតែពូម្នាក់ឬមាននរណាផ្សេង?

ស៊ាន់ៈ រត់ពីនាក់ មឿនមួយ កាលណាខ្ញុំជាប់ការងារ ខែនេះខ្ញុំមិនសូវរត់ទៅ ខ្ញុំដាំស្លដាំអីអញ្ចឹងទៅណា ហើយគេនោកន្លែងសួរចម្លើយ កាលណាខ្ញុំជាប់ដាំស្ល ដាំសណ្ដែកអញ្ចឹងទៅ គេប្រើតាមឿនហ្នឹងទៅ ហើយកាលណាខ្ញុំទំនេរ គេប្រើខ្ញុំ ខែស្ទូងខែដកអី ខ្ញុំមិនសូវបាននៅស្ទូងដកគេផង សួរឌុចទៅដឹងហើយ ស៊ីម សាំង អី ខ្ញុំមិនសូវនោកន្លែងផង គេដួសបាយទុកឲ្យ បានក្រោយគេរហូត បាយមិនសូវមូលគេផង ។

សុកគឿនៈ ពូរត់សំបុត្រហ្នឹង រត់ទៅដល់ត្រឹមណាខ្លះ?

ស៊ាន់ៈ ខ្ញុំរត់តែជុំវិញស្រុកត្រាំកក់ហ្នឹងហើយ តាមឃុំគ្រប់ភូមិហ្នឹងម៉ង ។

ភារិទ្ធៈ តាម៉ុកហ្នឹងធ្វើអី?

ស៊ាន់ៈ តាម៉ុកហ្នឹងភូមិភាគ តាម៉ុកយើងនេះ ។

ភារិទ្ធៈ មានដែលជួបមុខតាម៉ុកទេ?

ស៊ាន់ៈ ខ្ញុំជួប២ដង តាំងពីលឺតាម៉ុកៗមកជួបតែ២ដងទេ ។

ភារិទ្ធៈ ជួបពេលណាខ្លះ?

ស៊ាន់ៈ ខ្ញុំជួបពេលគាត់ កាលហ្នឹងធ្វើប្រឡាយ០១ម្ដង ។

ភារិទ្ធៈ ០១ហ្នឹងនៅឯណា?

សុាន់៖ ០១ខាងត្បូងតាកែវ ប្រឡាយជើងល្វេ ចំល្វេណា៎ កាលហ្នឹងខ្ញុំទៅធ្វើប្រឡាយនៅហ្នឹង ហើយជួបនៅអង្គការហ្នឹង ខ្ញុំយកសំបុត្រមកស្រុកហ្នឹង កាលហ្នឹងស្រុកគេកន្លែងពាណិជ្ជស្រុកហ្នឹងណានៅផ្សារអង្គការហ្នឹង ឲ្យគេហ្នឹង គាត់ជិះឡានមកជួបតែ២ដងហ្នឹង ហើយមិនដែលបានមាត់រកគ្នាទេ

ភារិទ្ធ៖ នរណាគេធ្វើពាណិជ្ជស្រុក?

សុាន់៖ ទេ ពាណិជ្ជស្រុកហ្នឹងអត់ស្គាល់គេ តែខ្ញុំរកសំបុត្រដាក់ត្រង់ហ្នឹងកាលហ្នឹងស្រុកកាលហ្នឹងតំបន់ក៏នៅបៀតហ្នឹង ស្រុកក៏នៅបៀតហ្នឹង ។

ភារិទ្ធ៖ អូ!

សុាន់៖ ខាងកើតអង្គការយើងហ្នឹងណា៎ ។

ភារិទ្ធ៖ នរណាគេប្រធានតំបន់?

សុាន់៖ តាគិត, តាគិតហ្នឹងបងតាជឹម, តាសានហ្នឹង ហើយដល់ក្រោយមកមិនដឹងនរណាទៀតមិនសូវដឹងដែរ តាជឹមហ្នឹងគេប្តូរគាត់ពីស្រុកត្រាំកក់ទៅចម្ការកៅស៊ូជប់ទៅ ។

ភារិទ្ធ៖ ចុះក្នុង៦នាក់ហ្នឹង អ្នករត់សំបុត្រតែពូ២នាក់ទេ ក្រៅពីហ្នឹងទៀតធ្វើអី?

សុាន់៖ គេ៦នាក់ហ្នឹងគេនៅខាងក្នុង គេធ្វើការគ្នាគេខាងក្នុង ខ្ញុំក៏មិនបានចាប់អារម្មណ៍ត្រួតពិនិត្យអីដែរ

ភារិទ្ធ៖ ពូមានដែលឃើញសម្លាប់មនុស្សអីទេ?

សុាន់៖ សម្លាប់ ខ្ញុំមិនដែលចុះផ្ទាល់ហ្នឹងគេផង អត់ ខ្ញុំក្មេងគេខ្លាចខ្ញុំមាត់ដាច គេមិនឲ្យខ្ញុំទៅជិតគេទេ ខ្ញុំកាលហ្នឹងនៅក្មេងជាងគេ ។

ភារិទ្ធ៖ មានដែលជួបប្រទះដោយចៃដន្យ ឃើញគេសម្លាប់ ឬគេបញ្ជាឲ្យពូសម្លាប់អីដែរអត់?

សុាន់៖ អត់ទេ គេមិនដែលប្រើឲ្យខ្ញុំសម្លាប់ទេ ព្រោះខ្ញុំនៅតូចជាងគេទាំងអស់ ហើយគេសុទ្ធតែធំៗ ហើយគេធំៗ តូចតែខ្ញុំមួយកន្លែងហ្នឹង គេមិនឲ្យទៅជិតទៅបៀតគេផង បានទៅលុបរណ្តៅគេធ្វើការ ហើយអញ្ចឹងគេឲ្យយើងទៅលុបទៅណា៎ ហ្នឹងបានទៅលុប បើបានទៅធ្វើអត់ឲ្យធ្វើទេ ។

ភារិទ្ធ៖ ញឹកញាប់ទេ?

សុាន់៖ មួយខែម្តងអីអញ្ចឹងដែរហ្នឹង ។

ភារិទ្ធ៖ រណ្តៅប៉ុនៗម៉ាន លុបហ្នឹង?

សុាន់៖ រណ្តៅវាមួយម៉ែត្រកន្លះ ២ម៉ែត្រអញ្ចឹងដែរ ។

ភារិទ្ធ៖ ប៉ុន្តែទំហំ?

សុាន់៖ ទំហំទទឹងមាត់រណ្តៅ២ម៉ែត្រ ទៅក្រោម១ម៉ែត្រកន្លះអញ្ចឹងទៅណា៎ ។

ភារិទ្ធ៖ ហើយពេលពូទៅលុបហ្នឹងពូឃើញយ៉ាងម៉េចខ្លះ?

ស៊ាន់៖ ឃើញគេកាប់ករ កាត់អីដាក់តម្រៀបអស់ហើយហ្នឹង លុបចង់ពាក់កណ្តាលហើយបានខ្ញុំលុបបន្ថែមឲ្យជិតឲ្យគេ បានទៅប្រឹតព្រៀងហ្នឹងគេអត់ទេ ។

សុកគៀន៖ កាត់ចេញពីខ្លួនម៉ងហេះ?

ស៊ាន់៖ បាទ!

សុកគៀន៖ កាត់មកតម្រៀបទេ?

ស៊ាន់៖ កាត់ករឲ្យហូរឈាមឲ្យអស់ ខ្មោចគេរើហើយ គេកាត់ករណា៎ ទៅឃើញម្តងកាលហ្នឹង ។

ភារិទ្ធ៖ ចុះឧបករណ៍ដែលគេសម្លាប់ហ្នឹងមានអីខ្លះ?

ស៊ាន់៖ មានតែចបកាប់គេហ្នឹង ហើយហ្នឹងភ្លាវទេះ ។

ភារិទ្ធ៖ ហើយកាំបិតគេកាត់ករ?

ស៊ាន់៖ ដាវ កាត់ករ ។

ភារិទ្ធ៖ នរណាគេជាអ្នកហៅពូទៅលុប?

ស៊ាន់៖ តាអាន់ ហ្នឹងតាពេញ ហើយតាចេងគេប្រធានៗហ្នឹងណា៎ ទាល់តែពេលទំនេទើបគេប្រើយើង ការងារគេញ៉ឹកអញ្ចឹងទៅ គេហៅយើងទៅ ។

ភារិទ្ធ៖ ហៅយ៉ាងម៉េច?

ស៊ាន់៖ ទំនេរដូចខ្ញុំអត់មានកិច្ចការងារក្នុងផ្ទះអញ្ចឹងណា៎ ខ្ញុំមកពីវាលអញ្ចឹងមក ថ្ងៃម៉ោង៤ម៉ោង៥គេហៅយើងទៅលុបអញ្ចឹងទៅ ។

ភារិទ្ធ៖ ចុះមានដែលដឹងប៉ុលីក្នុងចំណោមអ្នក៦នាក់ហ្នឹង សម្លាប់មនុស្សអីដែរអត់ទេ?

ស៊ាន់៖ អត់ទេ ៦នាក់គ្នាខ្ញុំអត់ទេ អត់ដែលធ្វើអីទេ គេអត់ប្រើម៉ង ។

ភារិទ្ធ៖ ចុះអ្នកដែលលុបរណ្តៅហ្នឹងនរណាខ្លះ?

ស៊ាន់៖ អ្នកលុបរណ្តៅច្រើនអ្នកទោសដូចថាសម្រាលទោសដូចជាតាដាំ ដូចជាអាសែន សួរអាសែនច្បាស់ហើយ ស្គាល់អាសែនទេ?

ភារិទ្ធ៖ ស្គាល់តើ ជួបគាត់ហើយ ។

ស៊ាន់៖ ហើយរឿងខ្ញុំសួរអាសែនទៅដឹងហើយសម្លាប់ប៉ុមិនសម្លាប់អីសួរតែអាសែនទៅដឹងហើយ រឿងខ្ញុំអត់សោះ ហា៎ ហា៎ អាសែនហ្នឹងនៅក្រោផ្ទាល់ម៉ង ដេកនៅអីជាមួយគ្នា ម៉ង ហើយវា...... ។

ភារិទ្ធ៖ សែនហ្នឹងអ្នកទោសតើអី?

ស៊ាន់៖ អ្នកទោសដែរ ។

ភារិទ្ធ៖ គាត់ខុសអីកាលហ្នឹង?

ស៊ាន់៖ ខ្ញុំអត់ដឹង ទៅដល់ឃើញតែអាសែននៅហ្នឹង មិនដឹងប៉ុន្មានឆ្នាំមកហើយ ៤-៥ឆ្នាំមកហើយមិនដឹង

សុកគឿនៈ ទៅមុនពូទៀត?

ស៊ាន់ៈ អើ! ទៅដល់ឃើញតែវានៅហ្នឹងដែរ សែនហ្នឹង ឃើញតែគេនៅហ្នឹងដែរ។

ភារិទ្ធៈ ពូសែនធ្វើអី?

ស៊ាន់ៈ អ្នកទោស។

ភារិទ្ធៈ ........ក្រៅពីកប់ខ្មោចហ្នឹង?

ស៊ាន់ៈ អត់មានធ្វើអីផងអ្នកទោស ឲ្យជួយលុបរណ្ដៅលុបអីហ្នឹងណា៎ កប់ហ្នឹងម៉ង។

ភារិទ្ធៈ ចុះពូមិនមែនអ្នកទោសផងគេឲ្យលុបរណ្ដៅដែរ?

ស៊ាន់ៈ បាទ ឲ្យទៅជួយលុបជួយអីហ្នឹង តែនៅក្រៅតែតាដាំហ្នឹងសែនហ្នឹងទេ

ភារិទ្ធៈ នៅក្រៅយ៉ាងម៉េច?

ស៊ាន់ៈ នៅក្រៅអ្នកទោសដែរតែនៅក្រៅ

ភារិទ្ធៈ អូ! អ្នកនាក់ហ្នឹងហេះ ចុះមានក្មេងៗនៅហ្នឹងទេហ្នឹង?

ស៊ាន់ៈ អត់ទេ

ភារិទ្ធៈ ក្មេងតូចអីណា៎?

ស៊ាន់ៈ មានតែក្មេងអ្នកទោសដែរ ប៉ុន្តែប៉ុន្មាននាក់ហ្នឹងអត់ស្គាប់ទេ ឥឡូវនៅរាល់ថ្ងៃហ្នឹង

ភារិទ្ធៈ នៅឯណា?

ស៊ាន់ៈ នៅយើងស្រែគ្រូ អាហ្នឹងម៉ែខ្ញុំគេសម្លាប់ចោលហើយហ្នឹង គេធ្វើមេទិញកាត់ទោសនៅហ្នឹងផ្ទះ។

ភារិទ្ធៈ អូ! ម៉េចអញ្ចឹង?

ស៊ាន់ៈ គាត់កាលពីឆ្នាំ៧៧ហ្នឹង ២នាក់ឪប្រកាសគាត់ឡើងធ្វើប្រធានភូមិថ្មីម៉ង ហើយកូនធ្វើប្រធានភូមិ ឪ អនុប្រធាន ដល់គេធ្វើប្រធានភូមិគេចាប់អាប្រធានឈ្លបក្នុងភូមិហ្នឹងណា៎ គេចាត់តាំងថ្មី ហើយយើងមិនមែនបុគ្គលិកយើងចាត់តាំងយ៉ាងម៉េច គេប្រជុំប្រជាជនមួយភូមិស្រែគ្រូ ប្រជុំហើយគេធ្វើមេទិញកាត់ទោសម៉ង

ភារិទ្ធៈ គាត់ទោសនរណាគេ?

ស៊ាន់ៈ កាត់ទោសឪវាហ្នឹង ឥឡូវម៉ែកូនវារួចមកវិញអស់ ម៉ែកូនអី។

ភារិទ្ធៈ ឈ្មោះអី?

ស៊ាន់ៈ ឈ្មោះខា, យាយញ៉ីប្រធានភូមិស្រែគ្រូហ្នឹង សព្វថ្ងៃគាត់ឈប់ហើយ គាត់ចាស់ហើយ៧០ជាយ ហើយមិនដឹង ជាមួយតាសាន តាសុនហ្នឹង។

ភារិទ្ធៈ ចុះម៉េចបានជាគាត់នៅរស់?

ស៊ាន់៖ គេលែងឲ្យគាត់មកវិញ គេដោះលែង តែប្តីគាត់ហ្នឹងកូនប្រុសាគាត់ស្លាប់២នាក់ហ្នឹង ហើយកូនស្រី ប្រពន្ធគាត់មួយ ដល់តែយើងបែកហើយ ប្រពន្ធហ្នឹងគេចូលសមាគមភូមិណា៎ ឥឡូវគេឡើងទៅនៅភ្នំពេញខាងទទួលភ្ញៀវបរទេស ឥឡូវគេចេញទៅបរទេសបាត់ទៅហើយ ប្រពន្ធអ្នកវង គ្រោះហ្នឹង ណា៎ គេទៅបរទេសបាត់ទៅហើយ ។

ភារិទ្ធ៖ ចុះយាយញ៉ុំហ្នឹងណា៎ កាលពីនៅក្នុងគុកគេឃុំឃាំងគាត់ដែរ?

ស៊ាន់៖ នៅតែយប់ទេ ។

ភារិទ្ធ៖ ចុះថ្ងៃគេឲ្យគាត់ធ្វើអី?

ស៊ាន់៖ ថ្ងៃស្ទូងដកអីខែស្ទូងណា៎ ខែប្រាំងដើរ មានឲ្យធ្វើអីខែប្រាំងអត់ទេ គាត់ចេះតែមើលគោអីជាមួយកូនគាត់ទៅណា ។

ភារិទ្ធ៖ ចុះពូថាគុក៣អាគាហ្នឹងសុទ្ធតែអ្នកទោសម៉េងអី?

ស៊ាន់៖ ហ្នឹងហើយ មានយកចេញយកចូលណា៎ ។

ភារិទ្ធ៖ គេរៀបម៉េចដែរគុកហ្នឹងកាលពីពេលពូនៅគុកហ្នឹង?

ស៊ាន់៖ គុកហ្នឹងគេរៀបត្បាញបន្ទាលួសយើងហ្នឹង ហើយហ្នឹងដញ្ជាំងក្តា ហើយហ្នឹងប្រក់ស្លឹក តែអា២ នោះ ប្រក់ក្បឿង យើង៧៥មកយើងមានក្បឿងណា៎ កាលពីមុនអត់ទេ ប្រក់ស្លឹក ។

ភារិទ្ធ៖ អាខាងប្រក់ក្បឿង?

ស៊ាន់៖ អាខាងកើត២បន្ទប់ប្រក់ក្បឿង ខាងលិចប្រក់ស្លឹក ។

អ្នកភូមិ៖ ឥឡូវនៅទេ?

ស៊ាន់៖ ហ៊ឺស! រុះអស់ហើយ ។

ភារិទ្ធ៖ ហើយមនុស្សគេឃុំម៉េចទៅ ពូឃើញ?

ស៊ាន់៖ គេដាក់មួយជួរ ម្ខាងមួយជួរ ២ជួរ ខាងជើងមួយជួរ ខាងត្បូងមួយជួរ គេទុកផ្លូវដើរប្រឡោះកណ្តាល ។

ភារិទ្ធ៖ ចុះបាយទឹកអ្នកទោសអីយ៉ាងម៉េចដែរ?

ស៊ាន់៖ បាយទឹកគេដាក់ហ្នឹងត្រឡោក ត្រឡោកចោះខ្សែ គេដួសដាក់ត្រឡោកហ្នឹង ត្រឡោកដូងយើងកាត់អញ្ចឹង តែត្រឡោកធំៗណាស់ ។

ភារិទ្ធ៖ គេចងជាប់គ្នាអញ្ចឹងឬយ៉ាងម៉េច?

ស៊ាន់៖ អត់ទេ គេចោះខ្សែចងយួរម្នាក់ៗណា៎ ដល់គេដួសហើយគេចែក ។

អ្នកភូមិ៖ ហើយព្យួរករ!

ភារិទ្ធ៖ អត់ទេ គេចងនៅជាប់ខ្នោះហ្នឹងហេះ?

សំាន់៖	អត់ទេ ត្រឡោកហ្នឹងដួសបាយហើយគេឃ្លួរ ចុះបបរ ចង់ហើយឃ្លួរទៅ ចែកម្នាក់១ៗអញ្ចឹងណា៎

ភារិទ្ធ៖	ចុះពូហ្នឹងនៅហ្នឹង ការហូបចុះ ការរស់នៅអីយ៉ាងម៉េចដែរ?

សំាន់៖	ខ្ញុំហេះ?

ភារិទ្ធ៖	បាទ ។

សំាន់៖	ហូបចុកធម្មតា ។

ភារិទ្ធ៖	ហូបត្រឡោកអីដែរអត់ទេ?

សំាន់៖	អត់ទេ ហូបហ្នឹងបាន ។

ភារិទ្ធ៖	ហើយមានអ្នកទោសមានគេឃុំឃាំងនៅក្រោមដីអីមានទេ?

សំាន់៖	កាលពីខ្ញុំទៅហ្នឹងអត់មានទេ បើកាលពីមុនៗមកមានកន្លែងគេដាក់មែន តែអត់មានដាក់ទេ កាលពីខ្ញុំ ទៅមក តាំងពីឆ្នាំ៧៦មកអត់មានទេ ។

ភារិទ្ធ៖	កន្លែងហ្នឹងនៅខាងណា?

សំាន់៖	គុកក្នុងដីហ្នឹង?

ភារិទ្ធ៖	បាទ ។

សំាន់៖	គេលុបអស់ហើយ តែគេជីកជម្រៅប្រហែលជា៥ម៉ែត្រហ្នឹង ប្រហែលជា២ម៉ែត្រការ៉េណា៎ គេធ្វើផ្ទះអញ្ចឹង គេប្រក់ក្បឿង ហើយគេត្បាញលួសតាំងពីបាត់រណ្ដៅហ្នឹងរហូតឡើងទៅលើទៅ ត្បាញលួស ឡើងអត់បានទេ ហើយគេធ្វើបន្ទប់ចាក់សោទៅណា៎ ។

ភារិទ្ធ៖	អាហ្នឹងតែម្នាក់ៗទេ?

សំាន់៖	តាមមើលតែម្នាក់ទេ បើនៅក្រោមតែមួយម៉ែត្រការ៉េដាង ។

ភារិទ្ធ៖	ចុះកាលពីពូទៅហ្នឹងប៉ុន្មាននាក់ទាំងអស់ ទាំងមេទាំងកូនចៅអី?

សំាន់៖	១២នាក់ ។

ភារិទ្ធ៖	ពូអាចរាប់ឈ្មោះបានទេ ១២នាក់ហ្នឹងឈ្មោះអីខ្លះ?

សំាន់៖	ឈ្មោះ អាន់, ឌុចធំ, ចេង ។

អ្នកភូមិ៖	ឌុចនេះហេះ?

ភារិទ្ធ៖	មិនមែនទេ ឌុចហ្នឹងនៅទួលស្លែងទេ មានដែលទៅទេ?

សំាន់៖	អត់ទេ អត់ដែរទៅទេ ។

ភារិទ្ធ៖	មានដែលឌុចគុកភ្នំពេញចុះមកដែរអត់ទេ?

សំាន់៖	អត់ទេ ។ មើល អាន់, ឌុច, ឈៀង, ពេញ, មឿន, ធួក, ឌុចតូច, សាំង, ស៊ីម, ទូច ហ្នឹងខ្ញុំ ហ្នឹង ។

ភារិទ្ធៈ	អូ! ១២នាក់ អញ្ចឹងអ្នកទោសគេបញ្ជូនមកញឹកញាប់ទេ?

ស៊ាន់ៈ	កាលហ្នឹងមួយខែគេច្រើនដែរ គេបញ្ជូនមកញឹកញាប់ ជំនាន់អាពតដឹងស្រាប់ហើយ ស៊ីមហ្នឹងបិះតែគេសម្លាប់ឪទេ ។

ភារិទ្ធៈ	ម៉េចអញ្ចឹង?

ស៊ាន់ៈ	គេថាឪក្បត់ម៉េចទេ កាលហ្នឹង ខ្ញុំអត់ដឹងដែរ ខ្ញុំមកឃើញឪវា ទៅប្រាប់វិញថាឪរបស់ស៊ីម ធ្វើម៉េច ដល់ហើយធ្វើរបាយការណ៍មកឃុំវិញ ឲ្យដោះលែងឪវាវិញ កុំអីស្រាប់ទៀតស៊ីមហ្នឹង ថាឪក្បត់ កាលហ្នឹងពាក់ព័ន្ធជាមួយពួកកំពង់សោម ។

ភារិទ្ធៈ	ពាក់ព័ន្ធយ៉ាងម៉េច?

ស៊ាន់ៈ	គេថាពួកកំពង់សោមកាលហ្នឹងក្បត់យ៉ាងម៉េច តាហោៗ ខ្ញុំអត់ស្គាល់គេដែរ គេថាក្បត់ហើយកូនចៅតាហោហ្នឹង គេឲ្យព្រលេងពីនោះមកដើររើសប្រពន្ធគេនោះ ម៉ាកង២០នាក់ឲ្យមក២០មកដល់ តែដើរយូរៗទៅវាលលាដតែអស់ទៅ គេថាក្បត់ជាតិ គេថាក្បត់មិនដឹងជាក្បត់របៀបម៉េច ខ្ញុំមិនដែលស្រាវជ្រាវគេដែរ អត់ ថាគាត់ដើររួមដៃរួមជើងជាមួយគេឲ្យបាយគេហូបហ្នឹងណា៎ ។

ភារិទ្ធៈ	កាលហ្នឹងឆ្នាំណា?

ស៊ាន់ៈ	ឆ្នាំ ៧៧-៧៨ហ្នឹង ។

ភារិទ្ធៈ	ចុះពូ អ្នកដែលធ្វើការនៅគុកហ្នឹង អ្នកដែលយាមការយាមអីហ្នឹង សុទ្ធតែនៅលីវឬមានប្រពន្ធហើយ?

ស៊ាន់ៈ	នៅលីវតែពួកខ្ញុំ៦នាក់ហ្នឹងទេ លីវទាំងអស់កាលហ្នឹងអត់ទាន់មានប្រពន្ធទេ កាលហ្នឹងមានតាអ៊ឹកមួយ ។

ភារិទ្ធៈ	សាំងមានប្រពន្ធនៅកាលហ្នឹង?

ស៊ាន់ៈ	កាលហ្នឹងនៅទេ ទើបតែប្ដេជ្ញាយើង៧៨នេះហើយទេ ស៊ីមក៏ប្ដេជ្ញាហ្នឹងដែរ ។

ភារិទ្ធៈ	ប្រពន្ធគាត់ធ្វើអី ពីរនាក់ហ្នឹង?

ស៊ាន់ៈ	សាំងប្រពន្ធគេធ្វើពេទ្យឃុំគុសហ្នឹងណា៎ ។

ភារិទ្ធៈ	ចុះស៊ីម?

ស៊ាន់ៈ	ស៊ីមប្រពន្ធនៅកងចល័តហ្នឹង ទើបតែប្ដេជ្ញាបាន២នាក់ហ្នឹង ឌុចតូចនេះក៏គ្មានដែរ ហើយអាទូចហ្នឹងប្ដេជ្ញាហើយរត់ទៅ បែកគ្នាទៅ រត់បែកគ្នាទៅ មកវិញគេលែងគ្នាហ្នឹងទៅ អត់យកគ្នាទៅ ។

ភារិទ្ធៈ	ទូចហ្នឹងនៅទាល់តែពេលបែកដែរ?

ស៊ាន់៖ អត់ទេ ពួកហ្នឹងកាលពីឆ្នាំ កាលពីប្រជុំថាវ៉ៃជាមួយយួនម្នាក់ទល់ហ្នឹង៣០នាក់ គេដកខ្ញុំ៥-៦នាក់ហ្នឹងចេញវិញ គ្មានទុកណាអត់ទេ គេដកទៅជួយទប់គេ ទៅជួយវ៉ៃគេ គេឲ្យទៅនៅកងពល ២១០ទៅ គ្នាដូចជា ឌុច, ខ្ញុំ, ទូចអីហ្នឹង គេដកចេញវិញ យើងធ្លាប់ធ្វើទ័ពណា៎ ។

ភារិទ្ធ៖ ឆ្នាំប៉ុន្មានគេដកចេញវិញ?

ស៊ាន់៖ ចុងឆ្នាំ៧៨ ដែលគេប្រជុំថាថែមកម្លាំងយកបុគ្គលិកខាងក្រោយ ។

ភារិទ្ធ៖ នរណាអ្នកប្រជុំ អ្នកនិយាយអញ្ចឹង?

ស៊ាន់៖ តាអាន់ហ្នឹង ។

ភារិទ្ធ៖ គេថាម៉េច?

ស៊ាន់៖ គេមករៀននៅតាកែវហើយ គេត្រឡប់ទៅវិញ គេថាទុកកម្លាំងខាងក្រោយបន្តិចបន្តួចបានហើយ យកកម្លាំងទៅទប់ហ្នឹងយួន ។

ភារិទ្ធ៖ រៀននៅតាកែវ រៀននៅកន្លែងណា?

ស៊ាន់៖ រៀនសាលានយោបាយហ្នឹង ឥឡូវគេដាក់សាលានយោបានដែរឥឡូវ កន្លែងខាងជើងមហោស្រព ខាងជើងសាលាLycée ហ្នឹង ដល់ហើយគេដកគ្នាខ្ញុំ៦នាក់ហ្នឹងចេញវិញ នៅសាំងមួយនៅជាប់ហ្នឹង

ភារិទ្ធ៖ អូ! ក្នុង៦នាក់ហ្នឹងនៅតែសាំងហ្នឹងទេ?

ស៊ាន់៖ ហ្នឹងហើយ ។

ភារិទ្ធ៖ គេដកនរណាខ្លះ?

ស៊ាន់៖ ដកខ្ញុំ, ស៊ីម, ឌុច, ទូចហ្នឹង, អ្នកហ្នឹង ។

ភារិទ្ធ៖ អូ! ដក៥នាក់ចេញនៅសល់តែសាំងមួយទេ?

ស៊ាន់៖ បាទ,

ភារិទ្ធ៖ ម៉េចបានជាគេទុកសាំងហ្នឹង?

ស៊ាន់៖ គេរត់សំបុត្រហើយគេធ្វើចុងភៅផង ដាំបាយដាំអីហ្នឹងណា៎,

ភារិទ្ធ៖ ហើយចុះគេដកទៅវ៉ៃ គេឲ្យទៅខាងណា?

ស៊ាន់៖ ទៅវ៉ៃហ្នឹងគេបុកចូលវ៉ៃចូលដល់កំពង់ជ្រៃហ្នឹងហើយ អាកំពុងជ្រៃខាងត្បូងតាកែវនេះ ទៅដល់ហ្នឹង ចូលទៅដល់បាញ់តែម្តង មិនមែនថាមិនទៅបាញ់ទេ ចូលទៅបាញ់ម៉ង វ៉ៃគ្នាត្រឹមហ្នឹងបេះបាក់មក រហូតទល់គ្នាហ្នឹងឡើងភ្នំហ្នឹងទៅ ។

ភារិទ្ធ៖ ចុះប្រធានកងពល២១០ហ្នឹង?

ស៊ាន់៖ ប្រធានគឺតាមាន ។

ភារិទ្ធ៖ ហើយចុះពេលវៀតណាមវ៉ៃចូលហ្នឹងពូភៀសខ្លួនទៅឯណាដែរ?

ស៊ាន់: ខ្ញុំរត់ចូលព្រៃ ចូលភ្នំលិច ។

ភារិទ្ធ: ខ្ញុំចង់សួរបកបន្តិច ពេលដែលពួងកហ្នឹង អ្នកទោសនៅហ្នឹងសល់ប្រហែលប៉ុន្មាន?

ស៊ាន់: អ្នកទោសសល់ប្រហែលជា៨០ជាង នៅសល់ហ្នឹងណា ពេលខ្ញុំចេញមកហ្នឹង ។

ភារិទ្ធ: ពួកភៀសខ្លួនទៅណាពេលដែលវៀតណាមវ៉ៃចូល?

ស៊ាន់: ខ្ញុំទៅដល់ឯរលាក់កងដើងណោះ ស្រុក៥១-៥២ណោះ ទៅដល់ស៊ីងឃ្លាច ។

ភារិទ្ធ: ទៅកាលហ្នឹងជាមួយឪពុកម្តាយបងប្អូនដែរអត់ទេ?

ស៊ាន់: រត់ទៅហ្នឹង ទ័ពហ្នឹងបេះតែទៅៗ ទៅដល់ហ្នឹងគេប្រាប់បន្តរៗគ្នាថា តាម៉ុកត្រូវរៀបកងពលនៅបុសតាផុងវិញ ឡើងវ៉ៃផ្សារថ្មី តាម៉ុកគាត់ថាអញ្ចឹងណា៎ ដល់ហើយគេថាយុវជន យុវនារីទៅមុខក៏អត់បានដែរ ត្រូវបកក្រោយមកវិញទាំងអស់ ខ្ញុំបកក្រោយវិញអត់ទៅណោះផង ទៅដល់ណោះបកក្រោយវិញ បកមកដល់បុសតាផុងរៀបកងថ្មីមែន ទាំងស្រីទាំងប្រុស ចាប់បំពាក់កាំភ្លើងសារជាថ្មីម៉ង ចាប់វ៉ៃសារជាថ្មីទៀតទៅ ហើយវ៉ៃតែក្នុងព្រៃដដែលហ្នឹង មានដែលបានចេញពីព្រៃឯណា អត់ទេ បើយួនដល់ព្រៃហើយ នៅតែក្នុងព្រៃដដែល ។

ភារិទ្ធ: ហើយអញ្ចឹងយ៉ាងម៉េចទៅ?

ស៊ាន់: អញ្ចឹងដល់ហើយខ្ញុំនឹកឃើញថាអត់បាយក្រហាយទឹកពេក អន្តរមានឯណា អន្តរមានម្នាក់ៗអស់អន្តរ២-៣កំប៉ុងរបស់ខ្ញុំនឹកឃើញថា ហេស! ខ្វិលទៅអីណាណាស់ ងាប់គ្មាននរណាមើល គ្មានពេទ្យអីដដែល ក៏នាំគ្នាចុះមកសារភាពមក សារភាពនៅឃុំត្រពាំងធំខាងត្បូង មកគ្នា១២នាក់មកសារភាពហ្នឹង មានកាំភ្លើង គ្រាប់បែក AK បេ មកសារភាពហ្នឹង ។

ភារិទ្ធ: ប៉ុន្មាននាក់ គ្នា៥នាក់ហ្នឹង?

ស៊ាន់: ១២នាក់ ហើយខ្ញុំក៏អត់ស្គាល់គេអស់ដែរ គេទើបតែមកថ្មី ។

ភារិទ្ធ: មកសារភាពនៅឯណា?

ស៊ាន់: សារភាពនៅភូមិត្រពាំងកក់ មកដល់ហ្នឹងគេធ្វើបាយ ធ្វើនំបញ្ចុកអីហូបអញ្ចឹងទៅ ហើយគេធ្វើសំបុត្រស្នាមមកដល់ផ្ទះមក ។

ភារិទ្ធ: ចុះពេលពួមកសារភាពហ្នឹង បានជួបជុំឪពុកម្តាយអីដែរអត់ទេ?

ស៊ាន់: មកជួបជុំទាំងអស់នៅភូមិហ្នឹងកាលហ្នឹងគេទើបតែជន្លៀសមកនៅភូមិមូលគ្នា ខ្ញុំថាមិនរស់ដល់សព្វថ្ងៃ ហ្នឹងផង មកដល់អន្តតានូគេលត់ជន្ទង់បាញ់៥ម៉ែត្រ ។

ភារិទ្ធ: អូ! ម៉េចអញ្ចឹង?

ស៊ាន់: គេឲ្យខ្ញុំអង្គុយ ក្រោយពីខ្ញុំសារភាពពីនោះមកហើយ ឲ្យអាវុធគេមកហើយហ្នឹង មកដល់អន្តតានូគេបាញ់ខ្ញុំ ។

ភារិទ្ធៈ	ម៉េចបានជាគេបាញ់?

ស៊ាន់ៈ	កាលហ្នឹងគេដាប់គុកនៅហ្នឹង ខ្ញុំថាចុះអាណាដាក់យូរម៉េចហ៎ បុកហ្អែងឲ្យចុយម្រាយអស់ទៅហ៎ គ្នាវាអ្នកវុញដែកហ្នឹងណា៎ វុញវនុកហ្នឹង ហើយម៉ោង១១ហើយខ្ញុំថាបុកហ្អែងឲ្យចុយម្រាយអស់ទៅ ក៏គេ អានោះលែងដៃ២បុកមែន ទៅបុកជើងអាហ្នឹង ហើយអានោះក៏ត្រូវរួចពីហ្នឹងមក ដោះលែងមកផ្ទះវិញ ហើយវាប្រធានសេនាជនភូមិនេះ ដល់មកដល់ជួបវាញ៉ាច់នៅអន្គតានូហ្នឹង ។

ភារិទ្ធៈ	ឈ្មោះអី?

ស៊ាន់ៈ	ឈ្មោះ តាវែត ។

ភារិទ្ធៈ	ដល់ហើយគេអត់ឲ្យខ្ញុំមកផ្ទះទេ គេបញ្ជូនទៅឃុំ ។

ប្រពន្ធៈ	រកបាញ់ចោលទៀតហ្នឹងណា៎ ។

ស៊ាន់ៈ	រកបាញ់ចោល ។

អ្នកភូមិៈ	អាហ្នឹងគេសងសឹកក្រោយពីជ័យជំនះ ។

ភារិទ្ធៈ	ហើយម៉េចបានជាគេអត់បាញ់?

ស៊ាន់ៈ	ពូខ្ញុំធ្វើសេនាជនអន្គតានូឳបខ្ញុំ មកដល់ឲ្យឪនិងខ្ញុំ ហើយកាលហ្នឹងឪខ្ញុំគាត់ប្រធានភូមិដែរ ប្រធានភូមិយើងបែកហើយហ្នឹងណា៎ ។

ភារិទ្ធៈ	ហ្នឹងក្នុងឆ្នាំ៧៩ហ្នឹងដែរហេះ?

ស៊ាន់ៈ	ឆ្នាំ៧៩ ។

ភារិទ្ធៈ	ខែប៉ុន្មានដែលគេប្រុងហ្នឹងបាញ់ហ្នឹង?

ស៊ាន់ៈ	ខែ៨-៩ ឆ្នាំ៧៩ ខែគេសាបស្រូវខ្លះស្ទូងហួសត្រពាំងហើយ ខែ៨ខែ៩ហ្នឹង ។

ភារិទ្ធៈ	ចុះកាលហ្នឹងខ្ញុំស្តាប់អត់បាន កាលហ្នឹងពូបុករនាបម៉េច គេដឹងម៉េច?

ស៊ាន់ៈ	ដាក់ទៅធ្វើការទៅស្ទូង ត្រឡប់ពីស្ទូងវិញ ស្ទូងជុំវិញមន្ទីរក្រាំងតាចាន់ហ្នឹងណា៎ ចេញមកពីស្ទូងវិញ វាដាក់ជើងយូរដាក់ម្នាង១ហ្នឹងណា ដាក់ហើយហូបបាយទាំងអស់គ្នា គេក៏ហូបបាយខ្ញុំក៏ហូបបាយ ដល់អាវែតហ្នឹងវាដាក់យូរដាងគេ ខ្ញុំថាហ្អែងដាក់មើល បុកឲ្យចុយម្រាយអស់មើល ។

អ្នកភូមិៈ	ពូឯងអ្នកថាអញ្ចឹង?

ភារិទ្ធៈ	អើ! អានោះបុក បុកហើយវាដោតជើងនេះ វាផ្ទប់ជាមួយបន្ទាលួសនេះ មុត ។

អ្នកភូមិៈ	បែក៧៩គេខឹងហ្នឹងមុតជើងហ្នឹង គេគំត្រន់ហ្នឹង ។

សុកគឿនៈ	នរណាគេអ្នកបុកកាលហ្នឹង ឈ្មោះអី?

ស៊ាន់ៈ	កាលហ្នឹងមិនដឹងនរណា....ឈឿន អ្នកបុក តែឈឿនអ្នកទោសដែរនិងណា៎ ។

ភារិទ្ធៈ	អូ! ចុះឈឿនអ្នកទោសម៉េចបានជាឲ្យបុក? អូ! យើងឲ្យអ្នកទោសហ្នឹងអ្នកទោស?

ស៊ាន់៖ យើងប្រើឲ្យរុញដែកហ្នឹងបន្តរ ដាក់ខ្មោះហ្នឹង ទៅរុញដែកបន្តរ ហើយវានៅខឹងខ្ញុំហ្នឹង គេបញ្ជូនខ្ញុំទៅដល់ស្រុកដល់អីណា៎ ដល់ស្រុកដល់ណា ជួបតាឆែកែវជួបអី តាឆែកែវនៅស្រុកត្រាំកក់ហ្នឹងណា៎ គេនៅអង្គុយបញ្ឈរកាំភ្លើងក្រោយខ្នងខ្ញុំអញ្ចឹង ខ្ញុំនឹកឃើញថាងាប់ចោលទៅ អត់មានស្តាយទេកាលហ្នឹង ងាប់ៗទៅ លែងនឹកឃើញរឿងស្លាប់ ខ្ញុំអត់ ដល់ហើយគេបញ្ជូនមកក្រោយវិញមកតាំងពី មកទល់នេះអត់មាននរណាមកដេញដោលអីអត់ ។

ភារិទ្ធ៖ ចុះដែលមានខាងណាគេចុះសួរនាំពូប៉ុន្មានដងដែរ?

ស៊ាន់៖ អត់ ទើបតែម្តងហ្នឹង តាំងពីបែកមកអត់ទេ ។

ភារិទ្ធ៖ អ្នកកាសែតអីអត់ដែលមាននរណាមកទេហេះ?

ស៊ាន់៖ អត់ទេ បើថាកាលពីខ្ញុំនៅពាក់ព័ន្ធ ប្រជុំនិន្នការញឹកខ្ញុំប្រជុំមួយខែ៣ដងទៅប្រជុំនៅឃុំហ្នឹងណា៎ កាលហ្នឹងស្រុកអីគេហៅទៅណែនាំ ទៅប្រជុំទៅ បើកាលនេះគេសួរចម្លើយខ្ញុំរហូតដល់ស្រុកដល់អីអស់ហើយ តាំងពីខ្ញុំមកដល់ណោះគេសួរនៅឃុំហើយគេបញ្ជូនទៅស្រុកទៀត ។

ភារិទ្ធ៖ ពូយល់ឃើញយ៉ាងម៉េចដែរកាលពីរស់នៅឆ្លងកាត់ជំនាន់៣ឆ្នាំ?

ស៊ាន់៖ យល់ឃើញថា បើចំពោះខ្លួនខ្ញុំម៉ងមានការឈឺចាប់ ហើយណាមួយយើងកាលហ្នឹងក៏ពាក់ព័ន្ធហ្នឹងជំហខ្លួនឯង បើនិយាយពីចងកំហឹងហ្នឹងខឹងដូចតែគ្នាហ្នឹង តែធ្វើម៉េចតែរស់នៅក្រោមការគាបសង្កត់របស់គេ បើគេថាយាម២ម៉ោង បើរូបគេនៅហ្នឹងគេឲ្យទន្ទេញតែប៉ុណ្ណឹង គេឲ្យទន្ទេញ ។

ភារិទ្ធ៖ នរណាគេឲ្យទន្ទេញហ្នឹង?

ស៊ាន់៖ អាន់ហ្នឹង ប្រធានហ្នឹង គេថារូបគេនៅហ្នឹង ហើយមែន អ្នកដែលយាមមុនៗក៏អញ្ចឹងដែរឲ្យតែរូបគេ យើងអ្នកយាមគឺមិនបាច់គេបង្ខំទេ ត្រូវតែទៅឯងអញ្ចឹងម៉ង ។

ភារិទ្ធ៖ អូ! រូបគេនៅយើង ក្បួនអ្នកយាមអញ្ចឹងហេះ?

ស៊ាន់៖ ហ្នឹងហើយ ក្បួនគេអញ្ចឹងម៉ង អ្នកយាមរូបគេនៅយើងអញ្ចឹងម៉ង ច្បាស់របស់គេអញ្ចឹងម៉ងហើយ មួយខែប្រជុំ៣ដង ពាក់ព័ន្ធពីការងារ ហើយមិនដឹងការងារធ្វើអី មិនដឹងពីការងារអីផង ។

ភារិទ្ធ៖ គេប្រជុំអីខ្លះ?

ស៊ាន់៖ ប្រជុំផែនការ និយាយពីការងារពង្រឹងគោលជំហរ ចងកំហឹង ចងគំនុំអីហ្នឹងណា៎ គេឲ្យពាក់ព័ន្ធអញ្ចឹងម៉ង ហើយឡើងធ្វើពាក់ព័ន្ធម្នាក់ម្តងៗគ្រប់ ។

ភារិទ្ធ៖ ចងជាមួយនរណាគេ?

ស៊ាន់៖ ចងជាមួយកាលហ្នឹងមានតែខ្មាំង ពាក្យថាខ្មាំង កុំឲ្យយើងចុះញ៉ មជាមួយខ្មាំង និយាយថាខ្មាំងម៉ងអត់មាននិយាយរឿងអីទេ ។

ភារិទ្ធ៖ ចុះជំនាន់ហ្នឹង អង្គការៗហ្នឹងនរណាគេ?

ស៊ាន់ៈ ពាក្យអន្តការរកមិនឃើញទេ មហាជនយើងទាំងអស់គ្នាសុទ្ធតែអន្តការ ហើយដល់ពាក្យអន្តការយើងថាតាម៉ុកហ្នឹងអន្តការ ដល់ពេលក្រោយមកគេថា យើងមានតាម៉ុកឯណា គេថាអន្តការភ្នែកម្ចាស់ យើងទាំងអស់គ្នាហ្នឹងខុសពីមាត់យើងទាំងអស់គ្នាហ្នឹងនិយាយទៅ ខុសពីយើងគ្រប់គ្នាហ្នឹង កាលហ្នឹងអន្តការទាំងអស់គ្នា ដល់ពេលអ្នកធ្វើរបាយការណ៍គេផ្សេង អាហ្នឹងក៏គេអន្តការដែរធ្វើម៉េច អញ្ចឹងថាពិបាកណាស់ជំនាន់ហ្នឹង តែអ្នកធំម៉ងមានតែឃុំ និងស្រុក ហើយនិងប្រធានកង ។

ភារិទ្ធៈ ចុះពូនៅហ្នឹងមានដែលឃើញគេចាប់រំលោភនារីភេទអីដែរអត់ទេ?

ស៊ាន់ៈ អត់ ។

ភារិទ្ធៈ ហើយ ពូយល់យ៉ាងម៉េចដែរពេលដែលខាងខ្ញុំចុះមកសួរនាំពូពីរឿងខ្មែរក្រហម?

ស៊ាន់ៈ មានយល់ថាម៉េច យល់ថាត្រេកអរច្រើន ប៉ុន្តែក្នុងអំឡុងនេះខ្ញុំយល់ថាចុះសួរខ្ញុំដូចជាវាក់អ៊ីដែរហ្នឹង ។

ភារិទ្ធៈ វាក់អ៊ីយ៉ាងម៉េច?

ស៊ាន់ៈ វាយូរហើយ វាអត់ភ្លេចអីទេ តែដូចថាវាភ្ញាក់ព្រើតដែរដល់អញ្ចឹង ។

ភារិទ្ធៈ គិតក្នុងចិត្តថាម៉េចដែរ?

ស៊ាន់ៈ មានគិតថាម៉េច ភ័យខ្លួនដែរហ្នឹងដល់អញ្ចឹង ភ័យខ្វះអត់ខ្វះហ្នឹង ។

អ្នកភូមិៈ អត់ទេដល់ពេលមកសួរអញ្ចឹងភ័យថា ខ្លាចគេយកទៅឯណាអីឯណាទៀតឬម៉េច?

ស៊ាន់ៈ ហា៎ ហា៎ ។

ភារិទ្ធៈ ពូមានការស្តាយក្រោយដែរ ដល់ពេលបានទៅធ្វើការនៅហ្នឹង?

ស៊ាន់ៈ ស្តាយអី ស្តាយថាគេបញ្ជូនទៅគ្មានបានការងារអី ដេកក៏គ្មានបានពេញភ្នែកហ្នឹងគេដែរ ការងារក៏យ៉ាប់ដែរកាលហ្នឹង ។

ប្រពន្ធៈ បើឯងមិនទៅគេយកទៅវ៉ៃចោល ។

ស៊ាន់ៈ ដែនការគេអញ្ចឹង ហើយខ្ញុំបើប្រកែកក៏មិនដឹងប្រកែកថាម៉េច ហើយខ្ញុំទៅដំបូងគេចាប់ មានស្ម័គ្រចិត្តចូលអីអត់ទេ សាំងក៏ចាប់ ស៊ីមហ្នឹងបិះហ្នឹងផាប់មួយសារ ស៊ីមហ្នឹងគេតាមចាប់បាញ់ចោលម៉ង

ប្រពន្ធៈ កាលពីប៉ាឯងទៅអាយុប៉ុន្មានដែរ?

ស៊ាន់ៈ អាយុ១៥-១៦ឆ្នាំហ្នឹង ស៊ីមហ្នឹងគេតាមចាប់ ដួបឯណាបាញ់ចោលកន្លែងហ្នឹង ស៊ីមហ្នឹងកាលហ្នឹង ស្របក់វ៉ៃតាកែវហ្នឹង គេថា ត-១១ក្បត់ហ្នឹង ។

ភារិទ្ធៈ ត-១១អីគេ?

ស៊ាន់៖ ទ័ពតំបន់តាកែវយើងពីមុនមានតែត-១១ទេ ឈ្មោះអាវៃៗហ្នឹង ដល់អាវៃក្បត់វត់ចូលទាហាន លន់ នល់ទៅ ហើយកូនទាហានហ្នឹងមកនៅយើងខាងនេះ គេតាមចាប់វៃចោល អាស៊ឹម វត់រួចអញ្ចឹងទៅ កុំបានគេជួយលាក់ អាស៊ឹមគេវៃចោលទាំងពីជំនាន់ហ្នឹងណោះ ។

ភារិទ្ធ៖ ចុះម៉េចបានជាគេតែងតាំង៦នាក់ហ្នឹងទៅក្រាំងតាចាន់?

ស៊ាន់៖ គេថែមកម្លាំងហ្នឹងទៅយាម ។

ភារិទ្ធ៖ ម៉េចបានគេតែងតាំង អ្នកហ្នឹងមានលក្ខណពិសេសអី?

ស៊ាន់៖ គេថាអ្នកហ្នឹងតស៊ូយូរមកហើយ អាពួកទ័ពមុនវាឡើងទៅអស់ទៅ នៅតែខ្ញុំ៦-៧នាក់នៅមួយកង ប្រចាំស្រុកត្រាំកក់ហ្នឹងណា៎ នៅមួយកងហ្នឹងនៅហ្នឹង គេរើសទ័ពចាស់ៗហ្នឹងណា យកមកយាម នៅហ្នឹងទៅ ។

ភារិទ្ធ៖ ចុះដំបូងពូមានដឹងថាកន្លែងក្រាំងតាចាន់ហ្នឹងកន្លែងសម្លាប់មនុស្ស កន្លែងឃុំឃាំងអីទេ?

ស៊ាន់៖ អត់ អត់ដឹងទេ ទាល់តែទៅវាក់អើម៉ង ។

## Cassette 2

ភារិទ្ធ៖ .....កន្លែងនគរបានក្រៅពីកន្លែងក្រាំងតាចាន់មានកន្លែងណាផ្សេងទៀតទេ?

ស៊ាន់៖ មានមួយកន្លែង កន្លែងគេសម្រាលទោស ។

ភារិទ្ធ៖ កន្លែងអីគេ?

ស៊ាន់៖ នៅអគ្គរការហ្នឹងម៉ង កន្លែងសាលារៀងហ្នឹង ។

ភារិទ្ធ៖ នរណាគេកាន់នៅអគ្គរការ?

ស៊ាន់៖ តាម៉េង ។

ភារិទ្ធ៖ តែម្នាក់ហ្នឹងទេ?

ស៊ាន់៖ ប្រធានគេតាម៉េងហ្នឹងមួយ នៅខាងលិចផ្សារអគ្គរការហ្នឹង កន្លែងគេហ្នឹង ក្រោយមកដឹងនរណា ទៀត អត់ដឹង ។

ភារិទ្ធ៖ ចុះពូយល់យ៉ាងម៉េចដែរ ដែលរបបខ្មែរក្រហមគេបំបាត់សាសនាចោល បំបាត់ទីផ្សារចោល?

ស៊ាន់៖ ខ្ញុំកន្លែងហ្នឹងមិនដឹងថាម៉េចទេនេះ គេយល់ឃើញធ្វើម៉េចរបៀបរបបគេបំបាត់សាសនាអញ្ចឹង ។

អ្នកភូមិ៖ នឹកឃើញថា ពិភពលោកទាំងឡាយអត់មានសាសនា អត់មានលុយចាយអញ្ចឹងទៅ ។

ស៊ាន់៖ បើលុយក៏គេបំបិទចោល ពុទ្ធសាសនាក៏គ្មាន ដឹងតែពីធ្វើទំនប់ប្រឡាយអញ្ចឹង បើវាដឹកនាំទៅអញ្ចឹង ហើយមិនដឹងជាថាយ៉ាងម៉េច ។

ភារិទ្ធៈ ចុះពូមានដឹងថាគេប្រុងនាំយកខ្មែរក្រហមមកកាត់ទោសដែរ?

ស៊ាន់ៈ ដឹងដែរ លឺគេផ្សាយរាល់ថ្ងៃ ស្តាប់ដែររាល់ថ្ងៃ ។

ភារិទ្ធៈ អូ! លឺតាំងពីពេលណាមក?

ស៊ាន់ៈ យី! រយៈពេលដូចជា៣-៤ឆ្នាំហើយ ។

ភារិទ្ធៈ អូ! ពូតាមស្តាប់មកយូរដែរហើយអញ្ចឹង?

ស៊ាន់ៈ បាទ ខ្ញុំស្តាប់ជាប់ ខ្ញុំបើវិទ្យុស្តាប់ជាប់ ។

ភារិទ្ធៈ លឺថាម៉េចដែរ?

ស៊ាន់ៈ លឺថា ប្រទេសអាមេរិកកាំង គេមកស្រាវជ្រាវកាត់ទោសមេដឹកនាំខ្មែរក្រហម លោកអីលោកអីទេ ខ្ញុំអត់ស្គាល់ហើយ ខ្ញុំភ្លេចហើយ ។

ភារិទ្ធៈ ចុះពូថាលឺកាត់ទោសហ្នឹង លឺគេថាយ៉ាងម៉េចខ្លះ?

ស៊ាន់ៈ លឺគេថាកាត់ទោសខ្មែរក្រហមៗ ប្រកាសរាល់ថ្ងៃ មិនដឹងជាកាត់ទោសនរណាៗបើខ្ញុំមិនសូវដែលតាមដានស្តាប់ដែរ ស្តាប់តែលឺកាត់ទោសៗ ។

ភារិទ្ធៈ ពូចាំមើលដែរអញ្ចឹង?

ស៊ាន់ៈ ចាំមើលដែរ ។

ភារិទ្ធៈ ពូយល់ថាការកាត់ទោសហ្នឹងវាចាំបាច់ដែរទេ សំរាប់ពូផ្ទាល់?

ស៊ាន់ៈ សំរាប់ខ្ញុំផ្ទាល់មានការចាំបាច់ខ្លាំង ព្រោះការកាត់ទោសខ្មែរក្រហមព្រោះដឹកនាំឲ្យកាប់សម្លាប់ប្រជារាស្ត្រ អ្នកស្លូតត្រង់ មានការឈឺចាប់យ៉ាងខ្លាំងដែរហ្នឹងចំពោះខ្ញុំ ។

ភារិទ្ធៈ ចុះបើសិនជាមានតុលាការហើយគេហៅពូទៅបំភ្លឺពីអ្វីដែលពូធ្លាប់ឆ្លងកាត់ជំនាន់នោះ ពូចូលរួមទេ?

ស៊ាន់ៈ ចូលរួមដែរ បើគេហៅហើយធ្វើម៉េច តាមដំណើរអញ្ចឹងទៅ ។

ភារិទ្ធៈ ពូយល់ថាមេដឹកនាំខ្មែរក្រហមគួរតែអត់ឱនទោសឲ្យដែរអត់ទេ?

ស៊ាន់ៈ ទេ គួរតែកុំអត់ឱនឲ្យ គួរតែកាត់ទោស ។

ភារិទ្ធៈ ចុះរាល់ថ្ងៃហ្នឹង ពូធ្លាប់លឺតុលាការកាត់ទោសហ្នឹង ពូលឺជាង៣ឆ្នាំហើយ ធ្លាប់លឺតែអត់មានអញ្ចឹងពូ ជឿថាតុលាការហ្នឹងអាចកើតមានទេ?

ស៊ាន់ៈ អាចកើតមាន ។

ភារិទ្ធៈ ចុះបើសិនជាតុលាការហ្នឹងមាន ពូយល់ថាអាចផ្តល់យុត្តិធម៌ចំពោះអ្នកដែលរងគ្រោះបានដែរអត់ទេ?

ស៊ាន់ៈ អាចផ្តល់បាន ។

ភារិទ្ធៈ ហេតុអី?

សាន់ៈ មិនដឹងហេតុអីទេដល់អញ្ចឹង ។

ភារិទ្ធៈ ពូយល់ថាការយកមេខ្មែរក្រហមមកកាត់ទោស ពូយល់ថាជាការសងសឹក ជាការចងកម្មចងពារដែរអត់ទេ?

សាន់ៈ មិនដឹងយ៉ាងម៉េចទេ កន្លែងហ្នឹងខ្ញុំដូចជាមិនហ៊ានថាទេ ហា៎ ហា៎ បើអត់ដឹងរឿងរបស់គេ នៅវែងឆ្ងាយ ព្រោះខ្ញុំថាទៅមិនដឹងជាថាម៉េចទេបើមេធំៗគេដឹកនាំ ។

ភារិទ្ធៈ ចុះបើសិនជាគ្មានតុលាការកាត់ទោស ពូយល់ថាគួរតែធ្វើម៉េចចំពោះមេដឹកនាំដែលដឹកនាំឲ្យមានការសម្លាប់មនុស្សអញ្ចឹង?

សាន់ៈ ត្រង់ហ្នឹងក៏ខ្ញុំមិនហ៊ានថា ។

ភារិទ្ធៈ ពូយល់ថាការកាត់ទោសខ្មែរក្រហមអាចធ្វើឲ្យសង្គមយើងប្រសើរ ឬប៉ះពាល់ដល់ការបង្រួបបង្រួមជាតិដែរអត់ទេ?

សាន់ៈ មិនដឹងយ៉ាងម៉េចទេ ខ្ញុំមិនហ៊ានថាទេ ព្រោះអីកន្លែងនេះវាពាក់ព័ន្ធដូចតាមស្តាប់វិទ្យុដូចជាពាក់ព័ន្ធច្រើន ខ្ញុំមិនហ៊ានថាទេ ខ្ញុំនិយាយអញ្ចឹង និយាយតែតាមមើលឃើញ ។

ភារិទ្ធៈ កន្លែងហ្នឹងកន្លែងតាកែវហ្នឹងហេះ?

សាន់ៈ អត់ទេនឹកឃើញថា អ្នកកាត់ទោសហ្នឹងមិនដឹងវាយល់សភាពការណ៍យ៉ាងម៉េចទេនៅក្នុងប្រទេសក្រៅប្រទេសខ្ញុំមិនអាចយល់ ។

ភារិទ្ធៈ ចុះពូតុលាការហ្នឹងគេប្រុងតែកាត់ទោស ដូចខ្ញុំប្រាប់ពូម៉ិញហើយ គេកាត់ទោសតែមេដឹកនាំហើយ ហ្នឹងបុគ្គលណាដែលទទួលខុសត្រូវខ្ពស់បំផុត អញ្ចឹងអ្នកថ្នាក់ក្រោមដូចពូអី គេអត់ទេ មិនអីទេ ពូមានធ្លាប់ដែលពូធ្លាប់ជួបប្រទះប្រាប់កូនចៅពូ ឬក្មេងជំនាន់ក្រោយទេ?

សាន់ៈ អត់ដែលនិយាយប្រាប់វាផង ។

ភារិទ្ធៈ ពូយល់រឿងរ៉ាវដែលពូជួបប្រទះហ្នឹងគួរតែឲ្យក្មេងជំនាន់ក្រោយដឹងដែរ?

សាន់ៈ ខ្ញុំអត់ដែលនិយាយប្រាប់ថាឲ្យដឹងរឿងអីអត់ ។

ភារិទ្ធៈ ប៉ុន្តែពូយល់ថាគួរតែឲ្យក្មេងជំនាន់ក្រោយដឹងលឺដែរ?

សាន់ៈ រឿងនេះអនាគតទៅគួរតែឲ្យក្មេងជំនាន់ក្រោយដឹងហើយ តែខ្ញុំអត់ដែល កូនចៅអីអត់ដែលឲ្យនិយាយ ។

ភារិទ្ធៈ ចុះការដឹងលឺហ្នឹងវាមានប្រយោជន៍អីខ្លះ?

សាន់ៈ ការដឹងលឺហ្នឹងមានតែពាក្យថា បើគេយល់ស្របហ្នឹងយើងគេពេញចិត្តហ្នឹងយើង ខ្លះគេមានគំនុំសងសឹកអញ្ចឹងទៅ ខ្លះក៏គេអធ្យាស្រ័យធ្វើម៉េចរបបសង្គមអញ្ចឹងទៅ អញ្ចឹងបានជាខ្ញុំអត់និយាយពិបាកដែរអាហ្នឹង ការឆ្លងកាត់មួយដំណាក់កាលទៅមួយដំណាក់កាល អារម្មណ៍យើងមើលមិន

ឃើញ ៣ឆ្នាំ ៨ខែ ២០ថ្ងៃដូចជាភ្លាមៗណា៎ អញ្ចឹងយើងមិនអាចយល់ទេ ចរិតមនុស្ស មិនដឹង គេចង់កម្រិតណា៎ យើងមិនអាចដឹង។

ភារិទ្ធៈ ចុះពូរស់នៅមកដល់សព្វថ្ងៃ ដូចថារបបខ្មែរក្រហមកន្លងផុតមកវាជិត៣០ឆ្នាំហើយ តើការរស់នៅក្នុងស្រុកក្នុងភូមិ ពូយល់ថាអតីតខ្មែរក្រហមដូចពូហើយហ្នឹងអ្នករងគ្រោះហ្នឹងរស់នៅសុខស្រួលអីដែរ អត់ទេ?

ស៊ាន់ៈ អត់មានផលវិបាកអីទេ ។

ភារិទ្ធៈ ហើយពូដែលដើរទៅក្រាំងតាចាន់អីទេ?

ស៊ាន់ៈ ទៅដែរ ទៅបុណ្យទៅទាន ទៅការអី គេហៅទៅវិញទៅមកអញ្ចឹង មុំហ្នឹងប្រជាជនស្រលាញ់ខ្ញុំចង់ស្លាប់ហើយមុំហ្នឹង មានអីទៅស្រុកហ្នឹងតាំងពី៧៩មក រត់មករកស្រូវខ្ញុំហូបមុំផ្ទល់ច្រើនគ្នាដែរ ទៅវិញទៅមក ខ្ញុំដើរ ខ្ញុំលក់ការ៉េមជាប់៥ឆ្នាំ កន្លែងណាក៏ខ្ញុំទៅដែរ ។

ភារិទ្ធៈ ពូចង់ឲ្យរឿងរ៉ាវដែលកើតមានហ្នឹង ឲ្យក្មេងជំនាន់ក្រោយដឹងលឺជ្រៅជ្រះដែរអត់ទេ?

ស៊ាន់ៈ ចុះមានអី ការអប់រំក្មេងជំនាន់ក្រោយ វាមិនបានលឺ មិនឃើញ គ្រាន់តែបានដឹងហ្នឹងណា ៎

ភារិទ្ធៈ ចុះតុលាការចំពោះពូផ្ទាល់ ពូយល់ថាមានប្រយោជន៍អីខ្លះសំរាប់សង្គមជាតិ សំរាប់សហគមន៍ពូដែលរស់នៅ?

ស៊ាន់ៈ តុលាការមានសារសំខាន់ណាស់ តែចំពោះរូបខ្ញុំមិនហ៊ានថាកន្លែងហ្នឹង នាំតែពិបាក សភាពការណ៍បច្ចុប្បន្ន អនាគតទៅមុខមិនដឹងយ៉ាងម៉េច វិនិច្ឆ័យយ៉ាងម៉េចខ្ញុំមិនអាចយល់ ។

ភារិទ្ធៈ ចុះពូ ការនាំយកមេដឹកនាំខ្មែរក្រហមកាត់ទោសហ្នឹង ពូយល់ថាវាអាចមានការបះបោរឲ្យមេដឹកនាំហ្នឹងរត់ចូលព្រៃ ហើយអូសអតីតអ្នកខ្មែរក្រហមឲ្យចូលទៅបម្រើខ្មែរក្រហម ដូចពូធ្លាប់ធ្វើខ្មែរក្រហមអញ្ចឹង បើសិនជាមានរឿងរ៉ាវអញ្ចឹង?

ស៊ាន់ៈ ខ្ញុំថាវាមិនអាចដែរ បានថាវាមិនអាចព្រោះកាត់ទោសមេ អាខាងក្រោមវាមិនអាចរើ រឿងណាបើវាទៅមួយជំណើរអស់ហើយ មានផែនការឯណាទៀតខ្ញុំមិនអាចដឹងទេ ។

ភារិទ្ធៈ ពូមានធ្លាប់គិតថាធ្វើម៉េចដើម្បីកុំឲ្យរបបហ្នឹងវិលមកវិញ?

ស៊ាន់ៈ ទេ របបហ្នឹង បើតាមខ្ញុំយល់គ្មានវិលថយក្រោយទេ មានតែទៅមុខ បើឆ្លងកាត់មួយដំណាក់ហើយ គ្មានវិលមកប៉ុលពតវិញគ្មានទេ។

ភារិទ្ធៈ ហេតុអី?

ស៊ាន់ៈ ដំណាក់កាលរាល់ថ្ងៃវាចូល Asean ក្រែងលោវាមិនអាចវិលអី គេវិលមកវិញក៏ខ្ញុំមិនអាចដឹងដែរ ខ្ញុំមិនហ៊ានថាទេខ្ញុំ ។

ភារិទ្ធៈ ចុះចំពោះពូផ្ទាល់ចំពោះពាក្យយុត្តិធម៌ពូយល់ថាម៉េច ស្អីទៅយុត្តិធម៌?

សាន់៖	យុត្តិធម៌យើងវាសាមគ្គីគ្នា ស្មោះស្មគ្រហ្នឹងគ្នា រួមរស់ជាមួយគ្នា សុខស្រួល សុខសប្បាយជាមួយ គ្នាហ្នឹង ។

ភារិទ្ធ៖	ចុះរស់នៅរាល់ថ្ងៃជាមួយគ្នាក្នុងសង្គមយើងមានយុត្តិធម៌នៅតាមរយៈតុលាការយើងសព្វថ្ងៃ?

សាន់៖	បើចំពោះរូបខ្ញុំគឺវាស្រួលពេកហើយ រាល់ថ្ងៃហ្នឹងគឺសុខស្រួលសប្បាយ ។

ភារិទ្ធ៖	ពូដែលមានរឿងក្ដីក្ដាំអីឡើងតុលាការដែរអត់ទេ?

សាន់៖	អត់ទេ សួរតែមេឃុំទៅដឹងហើយ គ្មានទេ សុខក៏ដោយសារមេឃុំ ពិបាកក៏ដោយសារមេឃុំដែរ ស្រាវជ្រាវខ្ញុំពី៧៩ដែរហ្នឹង ខ្ញុំមិនដែលមានផលរមាសពីមេឃុំឬពីណាអត់ទេ ផលរមាស់ដោយសារ អាវើតហ្នឹងមួយ ឥឡូវទៅហើយ ។

ភារិទ្ធ៖	ចុះរាល់ថ្ងៃដែលជួបគាត់ទៀតទេ?

សាន់៖	ជួបប្រពន្ធកូនគេ បងប្អូនគេ ទៅផ្ទះគេហៅផឹកដែរអីដែរហ្នឹងឥឡូវហ្នឹង យូរៗលែងអីវិញហើយ មួយក្ដួងហ្នឹង តែដល់ក្រោយមកស្រួលទាំងអស់គ្នា រៀបរាប់ទៅស្រែស្រឡាយបងប្អូនឯងដែរហ្នឹង ចប់ត្រឹមហ្នឹងទៅ ។

ភារិទ្ធ៖	ចុះពូអរគុណច្រើន ហើយខ្ញុំដូចជាអស់សំនួរអីសួរហើយ

សាន់៖	បាទ ខ្ញុំមានតែប៉ុណ្ណឹង ។

**-ចប់-**